DU
DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយចំណេះខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកចំណេះសាសនា: ព្រះគ្រូសុវណ្ណញាណ សួរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* ទំព័រ

លោក វ៉ាយ-ប៊ុក សមុហបញ្ជីធំ
នៅពុទ្ធសាសនបណ្ឌិត្យ — វីរបុរសតិះរូបទ្វីបអាស៊ី (តមក) ..... ៥៦១

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម — វិធីរក្សាកាយ តម្រូវតាមសេចក្ដីត្រូវការ
របស់ធម្មជាតិ (តមកនិងចប់) .... ៥៧៤

ឃុនសុទ្ធរមេធី ញូង-សឿង — ឯកសារាស្រ្តាត្រៃ ភាគទី ១៤ (តមក)... ៥៨៦

អ្នកឧកញ៉ាឥស្សរវង្សា សំ-ស៊ុន
នៅក្រុមប្រឹក្សាសាលាឧទ្ធរណ៍ — រឿងព្រេងខ្មែរ "រឿងអាធ្វូដឹង" (តនិងចប់).. ៥៩៤

*ផ្នែកសាសនា*

ព្រះគ្រូបញ្ញាលិខិត កៅ-ស៊ឹម
គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ — យុវចរិយាកថា (តមក) ....... ៦០៤

លោកឧបា សៅរ៍-ស៊ីវ — សុភាសិតនិងការពេភិទ (តមក) .... ៦១១

ឆ្នាំទី ១៩ — លេខ ១១ ខែវិច្ឆិកា (ណូវែម្ប្រ៍) ឆ្នាំ ១៩៤៧ — ថ្លៃជាវ ១ ឆ្នាំ ៣៥ រៀល

# វីរបុរសពីររូបទ្វីបអាស៊ី

## លោក វ៉ាយ-ប៊ុក

បានស្រង់ប្រែពីទស្សនាវដ្ដីបារាំង Extrême Asie ខែដេសេមប្រ៍ ឆ្នាំ ១៩២៤

និងខែយ៉ាំងវីយេរ ឆ្នាំ ១៩២៥

( តមក )

---

កសាងកិច្ចនៃការបដិវត្តន៍ ដែលលោកបានផ្ដួចផ្ដើមឡើងជាបឋម; ទើបគេអញ្ជើញលោកតាមប្រៃសណីយ៍ ឲ្យមកទទួលតំណែងជាប្រធានាធិបតីនៃសាធារណរដ្ឋចិន ហើយលោកក៏បានទទួលយល់ព្រម ហើយស្ថានភាពរដ្ឋាភិបាលបែបនេះ បានតាំងឡើងនៅប្រទេសចិន ក្នុងឆ្នាំ ១៩១២ ។

ពិតមែនតែលោកគ្រូពេទ្យ ស៊ុន យ៉ាត់-សេន មិនបាននៅក្នុងតំណែងប្រធានាធិបតីយូរអង្វែង ដោយលោកសុំលាចេញក្រោយរៀបសាធារណរដ្ឋជាកិច្ចធ្វើសម្រេចបានពេញទី ទើបលោក ស៊ុន-យ៉ាត់-សេន គួរបានទទួលជោគជ័យដ៏ឧឡារិក ក្នុងទំព័រសៀវភៅប្រវត្តិសាស្ត្រសាកល ។ ហេតុដូច្នេះ លទ្ធិសាធារណរដ្ឋចិន ក្នុងបច្ចុប្បន្នកាលនេះ ប្រែបប្រួលដោយកំហុសឬកិត្តិយស សឹងធ្លាក់ទៅលើគ្រូពេទ្យស៊ុនទាំងអស់ ។ បើសាធារណរដ្ឋចិនធ្វើការដោយល្អិតល្អន់ អ្នកទទួលខុសនឹងលោកស៊ុន-យ៉ាត់-សេននេះដែរ ។ នេះហើយដែលយើងជឿជាក់

តាមៈយោបល់យល់ឃើញជាពីរប្រការដែលជាសេចក្ដីសង្ខេបក្នុងជីវប្រវត្តិ (biographie) របស់អ្នកផ្ដាច់ការទិសខាងត្បូង (Dictateur du Sud) ។

បើពោលតាមប្រវត្តិសាស្ត្រវិញ ក្រោយដែលបានបាត់តាំងសាធារណរដ្ឋចិនរួចហើយ ហេតុតែទៅប្រទេសចិនមិនបានស្ងប់កបទាបទេ ត្រឡប់ជាមានសង្គ្រាមពលរដ្ឋជានិច្ចនិរន្ត តាំងពីឆ្នាំ ១៩១៣ មក ដោយហេតុលោក ស៊ុន-យ៉ាត់-សេន ជាមេបដិវត្តន៍ ជាប់ជានិស្ស័យប្រចាំសន្តានចិត្តរហូតមក ។

ហេតុនេះហើយ បានជាលោកមានកេរ្តិ៍ឈ្មោះល្បីល្បាញថាជាមេនយោបាយយ៉ាងសំខាន់ ប៉ិនប្រសប់ខាងការរៀបចំធ្វើបដិវត្តន៍ ប្រហែលជាមិនសូវប៉ិនប្រសប់ខាងការរៀបចំរដ្ឋាភិបាលក្នុងស្រុកទេ ប៉ុន្តែលោកជាមេបដិវត្តន៍យ៉ាងវិសេសវិសាលហើយ អាចធ្វើបានគ្រប់កាលផង ។ កាលលោកបានទទួលពាក្យទិន្នាពីពួកសមាជិក ដែលរួបរួមធ្វើការជាមួយគ្នា ដែលលោកមិនបានយកចិត្តទុកដាក់នឹងរដ្ឋាភិបាលទីងអនាគតនៃខេត្តក្វាងទុង ។ លោកតបវិញថា «មិនទាន់ដល់ពេលដែលត្រូវគិតបែបនេះទេ យើងត្រូវគិតតែស្រោចស្រង់ប្រទេសចិនសិន» ។ តើគំនិតបែបនេះ ជាការគិតខុសមែនឬ? យើងនឹងទម្លាក់កំហុសនេះដាក់លើបុរសនេះដោយស្រួលពុំទាន់បានទេ ព្រោះមានឧបសគ្គ និងហេតុបច្ច័យ

នានាប្រទេស ដែលមិនអាចចាត់ការឲ្យបានស្រេចទាន់ចិត្តបានក្នុងរយៈ ២ - ៣ ឆ្នាំប៉ុណ្ណោះ ក្នុងភាគដែនដីដ៏ធំទូលាយដូចជាប្រទេសចិននោះ ។

ដូច្នេះយើងគួរពិចារណាមើលថា សាធារណរដ្ឋចិនដែលតាំងបង្កើតឡើង ដោយស្នាដៃលោកដុកទ័រស៊ុន - យ៉ាត់ - សេន នោះប្រែពណ៌ឬទេ ? គួរចារិកនាមលោកទុកក្នុងពង្សាវតារថាជា វីរបុរស ១ របស់ប្រទេសចិន ឬជាអ្នកនាំឲ្យប្រទេសចិនបានសេចក្ដីទុក្ខលំបាកអាប់ឱនទៅវិញ ?

## ២ - មហាត្មគន្ធី

១ - ពណ៌នាដោយសង្ខេប អំពីកលិយុគ នៅប្រទេសឥណ្ឌា លោក R. d'Espic-Rac រៀបរៀង ។

ពួកអ្នកដឹកនាំយ៉ាងមធ្យមខាងលទ្ធិគណជាតិនិយមហិណ្ឌូក្នុងឱកាស មុននេះ បានធ្វើពាក្យពយការ ១ ច្បាប់ទៅរដ្ឋាភិបាលអង់គ្លេស ដែលមាន សរុបដោយសង្ខេបថា ពួកពលរដ្ឋឥណ្ឌាត្រូវការស្វ័យរាជ្យនិងស្ថានភាព ជាប្រជាធិបតេយ្យដោយដាច់ខាត ប្រសិនបើអង់គ្លេសគ្រាន់តែបានយកចិត្តទុកដាក់ការពារ កុំឲ្យប្រជាជាតិកាន់លទ្ធិជាតិនិយម ដែលមានសន្ដានចិត្ត ក្លៀវក្លាធ្វើការបេលាបលទៅបាន ។ ហេតុនេះ បើពោលដោយសំដីគ្រាត គ្រាតចំពោះស្ថានភាពនយោបាយនៅប្រទេសឥណ្ឌា មិនត្រូវនឹងមតិ របស់ជាតិអង់គ្លេសទេ ។ ពួកប្រជាជាតិឥណ្ឌាស្ទើរតែគ្រប់ថ្នាក់ទាំងអស់

មានបំណងតាមពិតត្រង់ចង់ធ្វើសិទ្ធិនយោបាយបានពេញលេញឡើង ។ សិទ្ធិនយោបាយបែបនេះ មានរាយការលោកម៉ុងតាគុយ (Montagu) បានប្រគល់ឲ្យហើយតាំងពីឆ្នាំ ១៩១៩ ហើយថាជនជាតិអង់គ្លេសក៏បានដឹងច្បាដែរ ។ ប៉ុន្តែក្នុងវង់រដ្ឋាភិបាល គេបានពោលសួរថា ពលរដ្ឋត្រូវការនយោបាយបែបឥស្សររដ្ឋ (Dominion) ឬជាបែបផុំបក្នុងបច្ចុប្បន្នដែលពលរដ្ឋមិនត្រូវការ ដើម្បីកុំឲ្យការបោលាបលខាងក្នុងប្រទេសមានឱកាសផុះខ្លាំងឡើង ។

បញ្ហារដ្ឋាភិបាលប្រទេសឥណ្ឌា នឹងបញ្ហាធ្វើតម្រូវតាមបំណងចិត្តរបស់ប្រជាជនឥណ្ឌា មិនមែនងាយស្រួលទេ ។

*

*  *

ពេលដែលកំពុងមានសង្គ្រាម នឹងឆ្នាំជំបូងដែលមានសន្តិភាព ហើយ ក្រស្តឥណ្ឌាបែកចេញជាពីរពួក គឺពួកមន្ត្រី, ពួកឈ្មួញ, ពួកធនាគារ ព្រមទាំងពួកអ្នកមានសតិបញ្ញា ប្រមូលគ្នាជាគណបក្ស ១ ហៅថាគណបក្សសេរីភាព (Parti libéral) ។ នយោបាយរបស់គណបក្សនេះយល់ថា ការសង្គ្រោះជាតិនឹងធ្វើទៅបានសម្រេច លុះត្រាតែរួបរួមគំនិតដោយបរិសុទ្ធចិត្ត នឹងការទុកចិត្តគ្នាទៅវិញទៅមកចំពោះប្រទេសអង់គ្លេស ដើម្បីចំរើនសេរីភាពនឹងសិទ្ធិរបស់ខ្លួនទៅតាមលំដាប់ ។

គណបក្ស ១ ទៀត ហៅថា គណជាតិនិយម (Nationaliste) ដែលនៅក្រោមបង្គាប់បញ្ជា លោកឧទ្ធីខង់ម៉ិត្តកក្តិរបស់លោក ដែលកាន់សា-សនាមហាហ្គ័ត ព្យាយាមធ្វើវិវឌ្ឍន៍ដល់ប្រទេស ដោយប្រើនយោបាយយ៉ាងសន្តិវិធី ដើម្បីបញ្ជាក់ប្រទេសអង់គ្លេសឲ្យយល់ថា ការដែលឲ្យមនុស្សចំនួនតិចបានសិទ្ធិអំណាចគ្រប់គ្រងជនជាតិឥណ្ឌា មានចំនួនដល់ ៦០០.០០០.០៤០ នាក់មិនបានស្ថិតស្ថេរចិរកាលទេ ។ ប៉ុន្តែគណៈបក្សនេះរលំរលាយអន្តរាយទៅ តាំងពីកាលដែលពួកការពារលោកគន្ធីទៅឃុំទុក ។ មានពួកបុលសេវិស្ត (bolcheviste) នៅក្រៅប្រទេសឥណ្ឌា និងពួកមហាហ្គ័តនៅអាស៊ីកណ្ដាល បានចូលមកក្នុងប្រទេសឥណ្ឌា បណ្ដាលឲ្យកើតចលាចលឡើង ។ ពួកនេះមិនព្រមប្រតិបត្តិតាមលទ្ធិ ដែលលោកមហាត្មៈបាននិយមផ្សាយ ដែលឲ្យទំទប់ទល់ដោយប្រើនយោបាយយ៉ាងសន្តិវិធី ទើបបណ្ដាលឲ្យកើតចលាចលខាងផ្នែកនយោបាយ ក្នុងឆ្នាំមុនៗនេះ ។

រដ្ឋាភិបាលអង់គ្លេសមុននឹងគណបក្សកម្មករ (Travaillistes ou Labour Party) ឡើងកាន់កាប់មុខក្រសួង បានប្រើឧបាយក្នុងក្រៅ ដើម្បីបំបែកពួកហិណ្ឌូ និងពួកមហាហ្គ័តឲ្យបែកសាមគ្គីគ្នា ។

ឯកិច្ចការដែលបានសង្កេតនៅប្រទេសទុគ៌ ដោយគេបានផ្ដាច់សម្ពន្ធកិច្ចរវាងពួកមហាហ្គ័តនៅឥណ្ឌា និងពួកមហាហ្គ័តនៅអង់គូរ៉ា (An-

gora) ។ ចំពោះប្រទេសអាហ្វកានិស្ថង់ (Afghanistan) គេបានបិទទ្វារនគរ ហាមមិនឲ្យពួកបុលសេវិស្ទ័ជ្រៀតចូលទៅបង្កការចលាចលបាន ហើយឃាំងមិនឲ្យនាំយកអាវុធយុទ្ធភណ្ឌ ទំនិញមាសប្រាក់ទៅប្រើការក្នុងការចលាចលនោះផងទេ ។

នៅប្រទេសឥណ្ឌា គេបានធ្វើឲ្យមេគណៈឥណ្ឌាខាងគណជាតិ-និយមឲ្យនៅក្រោមអំណាចបដោយឃនយោបាយផុយ តែមានបំណងដូចគ្នាគឺរូបរួមរដ្ឋាភិបាលអង់គ្លេសនឹងគណជាតិនិយម តែមិនត្រូវឲ្យពលដាលខូចសិទ្ធិជាតិអឺរ៉ុបនឹងជាតិអាមេរិកាំង ។

ក្រោយដែលបានបោះឆ្នោតក្រុមប្រឹក្សាខេត្ត (Conseils Provinciaux) ដែលមានពួកហិណ្ឌូចូលប្រដេញដើមដំបូងបង្អស់ គណរដ្ឋមន្ត្រីបានប្រគល់ឲ្យជាតិហិណ្ឌូពីរនាក់ជ្រើសតាំងបានទាំងពីរខេត្ត ។ ពិតមែនតែជាតិហិណ្ឌូទាំងពីរនាក់មិនព្រមទទួលការៈ តែជាហេតុបញ្ជាក់ឲ្យឃើញព្រមព្រៀង ក្នុងការរៀបចំរដ្ឋសភាខេត្ត ក្នុងអនាគតកាលទាំងប្រទេសអង់គ្លេសក៏តែសម្រុះសម្រួលបាន ក្នុងបញ្ហារដ្ឋធម្មនុញ្ញ ។ ក្រោយបន្តិចមកដែលលោកបាល់ដ្វាំង (Baldving) ចេញពីតំណែងនាយករដ្ឋមន្ត្រី ហើយលោកម៉ាក់ដូណាល់ដ៍ (M. Mac Donald) ឡើងកាន់ឈប់ការពេញទី ។ ពជការក៏បានដោះលែងលោកគន្ធី ។

លោកគន្ធីទៅជាមនុស្សផ្សេងដោយឡែក តាំងពីថ្ងៃដែលលោកចេញពីគុកមក, ដ្បិតក្នុងខណៈ ដែលលោកជាប់ឃុំ លោកមានជម្ងឺធ្ងន់ ។ ចិត្តលោករញ្ញកមិនហ៊ានប្រើកំឡាំង ហើយលោកបានឲ្យដំណើរតាមពួកកាសែតនិងតាមលិខិតដែលលោកបានផ្ញើទៅពួកមិត្តខាងនយោបាយរបស់លោក ថាគ្រាន់តែសុំឲ្យប្រទេសអង់គ្លេសប្រគល់សិទ្ធិខ្លះឲ្យមកពួកក្រុមជាតិនិយមយ៉ាំងមធ្យម (Nationalisme modéré) ដែលខ្លួនលោកធ្វើជានាយកគណបក្សនេះ ដើម្បីដឹកនាំប្រទេសទៅតាមវិន្យ័ធម៌ ។

រដ្ឋាភិបាលអង់គ្លេស ទើបនឹងព្រមក្នុងពេលឆាប់ៗ នេះអំពីរឿងតាំងគណកម្មាធិការ ១ ដែលមានសមាជិកច្រើនជាតិច្រើនគណៈផ្សំចូលគ្នា (Commission mixte) មានពួកមន្ត្រីខាងក្សត្រនិងពួកមេនយោបាយជាតិឥណ្ឌៀសម្រាប់ពិនិត្យមើលផ្ចាត់ឲ្យដឹងថា តើកិច្ចការកែប្រែលោកម៉ុងតាគុយ (les réformes de Montagu) សមតាមបំណងរបស់ប្រជាជាតិភាគច្រើនឬទេ ? តើគួរបន្ធូរនយោបាយបច្ចុប្បន្ន ប្រទេសអង់គ្លេសត្រូវប្រែយោបល់បែបណា សម្រាប់ប្រទេសឥណ្ឌៀ ដើម្បីធ្វើការឲ្យបានសម្រេចប្រយោជន៍ពិតមែន ហើយឆាប់រហ័សសមតាមបំណងនៃសេចក្ដីកែប្រែនេះ ?-

មួយវិញទៀត លោកឧបរាជប្រទេសឥណ្ឌៀ (Vice-roi des Indes) បានបញ្ចេញមតិ ចំពោះពួកគណជាតិនិយមយ៉ាំងមធ្យម (les éléments

modérés du nationalisme) ជាអ្នកមិនចាំបាច់គិតគូរឲ្យវែងឆ្ងាយទូលាយ អំពីសេចក្ដីព្រាងមតិផ្ទួសគា ដែលលោកម៉ុងតាគុយ ផ្ដើមធ្វើឡើង និងការផ្ដាច់សម្ពន្ធកិច្ច ដែលជាតិតាំងពីព្រេងបុរាណប្រស្រ័យនឹងគ្នាមកយូរហើយនោះទេ គង់តែអ្នកត្រូវលឿនទៅមុខបាន ។

ការដែលខំប្រឹងប្រែងតាំងរដ្ឋាភិបាលកម្មករ (Gourvernement travailliste) មិនបានសម្រេចប្រយោជន៍ក្នុងការរួបរួមគណៈជាតិនិយមឥណ្ឌា តាមកម្មវិធី ដែលគណៈនេះបានបញ្ចេញមតិ ក្នុងសម័យបើកប្រជុំគណៈកម្មាធិការហើយជាកម្មវិធីរបស់ប្រជាជាតិឥណ្ឌានោះទេ ត្រឡប់ជាមានហេតុទាស់ទែងខ្វែងគំនិតគ្នាយ៉ាងសំខាន់ ។ ពួកមហាហ៊ុននិងពួកហិរញ្ញិក មានបំណងចង់តែរដ្ឋាភិបាលតាំងស្រុង ផ្សាយនយោបាយដោយតារុណកម្ម ជួយគាំទនយោបាយអង់គ្លេស ។

ក្នុងកាលសមន្និបាត ពួកនេះមាននយោបាយផ្សេងៗព្រមតាំងវិធីពិឃាតជីវិតមនុស្សជាវិធីដែលអាចធ្វើឲ្យរដ្ឋាភិបាលអង់គ្លេសដែលមានបរិយាបរិនភាពកោងចាកចេញពីឥណ្ឌាបាន ហើយនាំគ្នាមកប្រជុំធ្វើបុណ្យជាកិត្តិយស ចំពោះវីរបុគ្គលស្នេហាជាតិតាំងឡាយ ។ កិរិយាប្រព្រឹត្តយ៉ាងដូច្នេះ ទុកជាទិដ្ឋានុគតិរបស់ពួកយុវជន ហើយប្រកាសផ្សាយដល់ពួកនិស្សិតមហាវិទ្យាល័យផង ។

ប៉ុន្តែពួកលោកគន្ធីនិងពួកសាវ័ករបស់លោក ដែលបេះដូងខាង ផ្នែកនយោបាយខ្លះយល់ថា សម័យក្រោយនេះ មិនអាចញ៉ាំងរដ្ឋាភិបាល អង់គ្លេស គណៈរក្សាជាតិ (Conservateur), សេរីភាព (liberal) កម្មករ (Travailliste) ឲ្យកែប្រែបច្ចេកញ្ញត្តិខ្លួនឡើយ ។ លោកគន្ធីនិងសាវ័ករបស់ លោកជឿថា ការធ្វើដូច្នោះ ជាហេតុនាំឲ្យខូចពាក្យសុំរបស់ប្រជា-ជាតិឥណ្ឌា គឺការកែប្រែភាពកម្មការផ្ដាច់ខ្លាំងទៅវិញ ហើយបែរ ជានៅស្មើមាៗ ប្រហែលជាបានផលប្រយោជន៍ក្នុងការតាមការគ្រាន់បើ ជាជាង ។ ហេតុនេះបានជាលោកគន្ធី និងសាវ័ករបស់លោក ខំប្រឹង ព្យាយាមចំណុចលានពតិមានដូចពោលមកនេះ ហើយឲ្យឈ្មោះពួកកំរិ-ក្ខុអហេតុគចិត (les Radiceaux irréductibles = ពួកសុំតក់កែប្រែប្រែប តាំងស្មើ) ថាជាបច្ចាមិត្ត ដល់កិច្ចការនយោបាយ ក្នុងការតាំង ស្វ័យពក្ស ដែលប្រជាជនឥណ្ឌាបានស្រេចសុំតក់មកនេះ ។

ដំណើរដែលគេបានទទួលមកពីប្រទេសឥណ្ឌា គេស្មានយល់ថា លោកគន្ធីកាន់តែថយដៃហើយ ពីព្រោះព្យាយាមការកែសេចក្ដីពិតប្រាកដ ហើយលោកមិនទាន់ជាសះស្បើយ អំពីកេតដែលត្រូវវះកាត់ពោះដែល គេយល់ថា លោកមានអានុភាពកាន់តែខ្សត់ខ្សោយដោយហេតុៈ

១) អាការទុព្វលភាពនៃកាយ ២) ការហោសនាយ៉ាំងម៉ឺងមាត់ ខ្លាំងពេក នៃពួកគណៈបក្សសុយបែរ កំឌកូ (les super radicaux = គណៈ

បដិវត្តន៍យ៉ាងៗ (ក្តី) ។ ហេតុដូច្នេះ បានជាលោកតិលកនិងការ សម្រេចដាច់ខាតចំពោះការរួបរួមគ្នា នៃរដ្ឋាភិបាលអង់គ្លេសនិងគណៈ បដិវត្តន៍យ៉ាងមធ្យមជាតិឥណ្ឌា (Radicaux Modérés indiens) ។

បញ្ហាជាតិឥណ្ឌានេះ មិនមែនងាយនឹងដោះស្រាយដូចជាពួកខ្លះ យល់នោះទេ ។ ខ្ញុំសុំពោលម្តងទៀតថា បញ្ហានេះមិនមែនមកពី ពួកការអង់គ្លេសមិនព្រមអនុញ្ញាតឲ្យប្រជាជន មានសតិបញ្ញាចូលទៅ កាន់កាប់ការរដ្ឋាភិបាល ដោយស្នេហាជាតិនេះម្យ៉ាង ។ ម្យ៉ាងទៀត មិនមែនមកពីប្រជាជនមានទុក្ខលំបាកខំព្យាយាមតវ៉ាយកសិទ្ធិយ៉ាងមធ្យម ក៏ឥតអង្គឹមានទ ។ បញ្ហាដែលសំខាន់បំផុត គឺក្នុងពេលបច្ចុប្បន្ននេះ គេត្រូវ ការមនុស្សណាដែលមានអានុភាពខាងរយោបាយសម្បត្តិ និងធម្មបរិយា សម្បត្តិល្អមនឹងផ្គុំសន្តិសញ្ញា តាមបំណងរបស់ប្រជាជនភាគច្រើនជា មួយរដ្ឋាភិបាល ដែលមានបំណងនឹងធ្វើកិច្ចបរបាដោយសេរីភាព ដូចជា រឿងលោកចៅហ្វាយស្រុកបេនសាប (Pendjab) ឈ្មោះលោកអូដ័ស្សយែរ (O Dssyer) មានជោគជ័យឈ្នះក្តីនៅក្រុងឡុងដ៍ អំពីរឿងធ្វើឲ្យខូច កិត្តិយស ដែលគណៈបក្សយ៉ាងមធ្យមនិយមជាតិបានប្រព្រឹត្ត ។ រឿង នេះនាំឲ្យយល់ឃើញថា វិធីប្រឆាំងសផ្សាយដែលគណៈបក្សជាតិនិយម បានធ្វើហួសប្រមាណក្នុងរៃមុនៗនេះ ។ លោកចៅក្រមបានថ្លែង ពន្យល់ថា លោកអូដ័ស្សយែរ នឹងរកបញ្ហាសារកនិទ័ពនៅកម្រិត

សារ គ.ស. ១៩៦៨ បានបំពេញកិច្ចនេះ ក្នុងស្ថានការយ៉ាងលំបាកណាស់ ចំពោះពងការអង់គ្លេស ដោយលោកឃើញថា លោកបានជួបទឹងពួកផងជាតិដ៏កាចសាហាវជាច្រើន ទើបលោកត្រូវតែប្រើកម្លាំងតទល់ទឹងពួកនោះ ។ ១ ឆ្នាំខាងក្រោយកើតហេតុភេទនៅអម្រឹតសារ ហើយ មានគណៈកម្មការ ១ ក្រុម បានចូលមកស៊ើបសួរពិនិត្យរឿងនោះឡើងវិញម្តងទៀត ហើយសម្រេចសេចក្តីថា ការប្រព្រឹត្តរបស់លោកនាយពលឯក ទឹងលោកចៅហ្វាយខេត្តនោះមិនសមរំសោះ ។ ដល់ ៥ ឆ្នាំក្រោយមកទៀត ទើបពៅក្រមអង់គ្លេសដែលមានចិត្តទូលំទូលាយសុចរិត បានថ្លែងមតិដោយយល់ច្បាស់នូវហេតុការណ៍ក្នុងសារ-ក្រមកាត់សេចក្តី ហើយក៏បានដំឡើងកិត្តិយសលោកមន្ត្រី ទឹងឆ្មាយទាហាននោះឲ្យតាំងនៅតាមដំណែងដើមវិញ ។

នេះហើយ ជារឿងដែលគួរពិនិត្យវាថ្ល ដែលនាំឲ្យយើងយល់ថា ស្រមោលតាំងអស់មិនមែនមានមកតែខាងពួកអង់គ្លេសម្ខាងទេ ហើយមិនត្រូវគិតគូរតែពន្ទឹតែប៉ែកខាងគណៈជាតិនិយមប៉ុណ្ណោះទេ ។ ហេតុដូច្នេះ យើងត្រូវព្រមទទួលជឿថា ការដោះស្រាយបញ្ហានេះឲ្យបានសម្រេច លុះត្រាតែទាំងពីរផ្នែកខ្ទះខ្លួនត្រូវត្រាជួនវិញ្ញាណសត្វខ្លួន ហើយលះបង់គំនិតដែលនាំឲ្យពាសវែងខ្វែងគំនិតគ្នាចេញ រួបរួម

សាមគ្គីតាមផ្លូវកណ្តាល ដែលនាំឲ្យប្រជាជាតិបានសន្តិសុខស្ថិតស្ថេរទៅអនាគត ។

## ២ - ការផ្តើមតាំងស្វ័យរាជ្យនៅប្រទេសឥណ្ឌា និង ការបោះឆ្នោតអង់គ្លេស

តាំងពីគ្រាមហាសង្គ្រាមលើកមុននេះ ប្រទេសឥណ្ឌាបានឈានចូលទៅខាងមុខនានៃនយោបាយសាកលលោក ជាប្រទេសមានស្ថានភាពយ៉ាងមាំមួនខាងផ្លូវនយោបាយ ខាងសេដ្ឋកិច្ច, វណ្ណកិច្ចដែលពួកមហាអំណាចមិនអាចចូលទៅចាប់ផ្តល់ជូនវិញ្ញាណបាន ។ ប៉ុន្តែក្នុងបច្ចុប្បន្នកាលនេះ ប្រជាជាតិឥណ្ឌាបានយល់ហេតុការណ៍សព្វគ្រប់ ដោយហេតុរឿងរ៉ាវនៅប្រទេសនេះ ជាប្រយោជន៍ក្នុងសកលលោកទាំងមូល បានជាមហាជនត្រូវគិតមិនត្រូវនៅស្ងៀមព្រងើយកន្តើយទេ ។

ពាក្យថា «ស្វ័យរាជ្យ» ប្រែថា «ត្រួតត្រាដោយខ្លួនឯង» ។ គេយល់ថា (Autonomie) ជាពាក្យដែលមានប្រើឡើងជាបឋម កាលពីក្នុង គ.ស. ១៩០៦ នៅមហាសន្និបាតប្រជាជាតិឥណ្ឌូ ក្រុងកាល់កុត្តា (Congrès national hindou de calcutta) ។ លោកបាលគង្គាធរតិលក (Bal Gangdhar Telok) អនិច្ចកម្មទៅតាំងពីខែអ៊ូតឆ្នាំ ១៩២០ ដោយអត់ភោជនាហារក្នុងខណៈដែលជាប់ឃុំឃាំងបួនដង ។ លោកនេះជាមេគំនិតមួយដែលបានផ្តើមតាំងស្វ័យរាជ្យឡើង ជាអ្នកខ្នះខ្នែងយ៉ាងម៉ឺងម៉ាត់ក្រៃ

អស់ជីវិត ។ តែថែបការពារនៃគណបក្ស "ស្វ័យរាជ្យ" សព្វថ្ងៃបានចាត់តាំងបះភ្ញើតឡើង កាលពីក្នុងរវាងចុងមហាសង្គ្រាមលើកទី ១ មុននេះ ។

ក្នុង គ. ស. ១៩១៧ ប្រទេសអង់គ្លេស ត្រូវការចង់បានពួកទាហ៊ានក្រុមពិជ័យសង្គ្រាមជាច្រើន ទើបចូលទៅប្រស្រ័យទឹនប្រទេសឥណ្ឌា ហើយបានស្រូបយកកំឡាំងរេហ៍ពលពីប្រទេសនេះទៅ ប៉ុន្តែត្រូវធ្វើអំណោយឬធ្វើសញ្ញាអ្វី ១ ឲ្យជារង្វាន់ដល់ប្រជាជាតិឥណ្ឌា នេះហើយជារបៀបសេចក្តីកែប្រែរបស់លោក ម៉ុងតាគុយ-សេលមេសហ្វ័រ (Réformes Moutagu-Chel nesford) ។

ដល់ធ្វើសង្គ្រាមមានជោគជ័យ រដ្ឋាភិបាលប្រីតាន្និកប្រែប្រួលទៅតាមសម័យនិយម ។

ប៉ុន្តែសេចក្តីកែប្រែបញ្ចប់ប្រពៃណី មិនត្រូវទឹងបំណងរបស់ប្រជាជាតិឡើយ, ការតាំងរដ្ឋសភា (Parlement) មានចំនួនច្រើនជាង ២ ភាគក្នុង ៣ ភាគ ដែលរដ្ឋាភិបាលមានសិទ្ធិជ្រើសតាំង មិនមែនផ្លាស់ប្តូរសិទ្ធិពួកប្រកាន់លទ្ធិប៊ុយរ៉ូក្រាទី (Bureaucratie) ដែលធ្លាប់និយមធ្វើមកយូរណាស់មកហើយនោះទេ ។

(មានត)

វិធីរក្សារាងកាយ

# តម្រិតាមសេចក្ដីត្រូវការរបស់ធម្មជាតិ

ហ្លួងទិពនូមន្ត្រី ញ៉ុក-ថែម ប្រែរៀបរៀង

(តមកនិងចប់)

---

ឯការដកដង្ហើមនោះ ជាកិច្ចសំខាន់បំផុត ក្នុងការនាំជីវិតឲ្យប្រព្រឹត្តទៅបានស្រួល ដូចយើងបានពោលមកហើយក្នុងផ្នែកអាកាសថា មនុស្សយើងត្រូវការអាកាស ប្រហែលនឹងអាហារដែរ ហើយអាកាសនោះ ជាអាកាសឧក្សីហ្សែនដោយច្រើនបំផុត ។ សួតរបស់យើងស្រូបយកអាកាសចូលទៅហើយ វាក៏នឹងទទួលយកចំពោះអាកាសឧក្សីហ្សែនទៅទុកក្នុងពង់ឈាម ហើយនៅខណៈនោះ បញ្ចេញអាកាសកាគ្រក់ចេញមកខាងក្រៅ ។ ការបន្ទោបង់វត្ថុឥតគុណប្រយោជន៍ ចេញមកតាមផ្លូវដកដង្ហើមនេះ មិនមានអ្វីមកទទឹងទាស់ទេ ប្រសិនបើទទឹងនឹងការដកដង្ហើមហើយ នឹងក្រៀនក្រយដោយឆាប់មិនខាន ។ ការផ្ដួចការបន្ទោបង់គ្រឿងស្មោកគ្រោកតាមផ្លូវដកដង្ហើមនេះ យើងមានឱកាសជួយជ្រោមជ្រែងបានខ្លះដែរ ដោយការរើសទីលំនៅដែលជាទីស្រឡះ មានអាកាសល្អ អាកាសអាចផ្ទេរចេញចូលបានដោយស្រួល មិនមែនជាទីស្អុះស្អាប់ទាល់តែដកដង្ហើមមិនបានស្រួល ។ ប្រសិនបើយើងនៅក្នុងស្ថានបែបនេះ ទើបការដកដង្ហើមប្រព្រឹត្តទៅបានដោយស្រួល ។

ការបន្ទោបង់គ្រឿងស្មោកគ្រោក ក្នុងកាយតាមផ្លូវញើស ក៏ជាកិច្ចសំខាន់មួយដែរ ។ ការទប់ទល់មិនឲ្យញើសក្លួលចេញពីក្នុងកាយ ក៏មានទោស ប្រហែលគ្នានឹងការទំនត់ធ្នត់មិនបន្ទោបង់ឧច្ចារៈនុះដែរ ។

## អំពីការសំអាត

ការសំអាតនេះ សំដៅដល់ការសំអាតគ្រឿងស្មោកគ្រោកហូតដល់ក្លិនអាក្រក់ផ្សេងៗដែលប្រទុស្សរ៉ាយដល់នាសិករបស់យើង ។ ការសំអាតនេះតួរចែកចេញជា២ប្រភេទ គឺសំអាតដោយភ្នែកឃើញប្រភេទ ១ សំអាតមេរោគប្រភេទ ១ ។

សំអាតដោយភ្នែកឃើញ. — សំដៅដល់ការសំអាតមិនឲ្យមានគ្រឿងស្មោកគ្រោក ដែលមើលឃើញដោយភ្នែក ឬធុំក្លិនអាក្រក់ដោយច្រមុះ ។ ការសំអាតប្រភេទនេះ ក៏រមែងមានគុណដល់កាយយើងជាអនេកប្រការ ព្រោះជាការនាំឲ្យកាយយើងស្រួលសប្បាយហើយមានចិត្តគំនិតផូរផង់ល្អ ។ ឯការសំអាតកាយនោះ យើងបានពោលមកហើយថា ជាជំនួយឲ្យចេញញើសពីខ្លួនដោយងាយស្រួលឡើង ។

គ្រប់ៗ ចំណែកនៃកាយយើង ត្រូវតែដុសខាត់សំអាតជានិច្ច តាំងពីសំពត់អាវស្បៀកពាក់ ក៏ត្រូវតែដុសលាងសំអាតហាលអ៊ុតជានិច្ច

គេហៅស្អាតសោតទៀត ត្រូវប្រាសនិងផុតសំអាតឲ្យប្រាសចាកល្អងធូលី និងគ្រឿងស្មោគគ្រោកផ្សេងៗ គ្រឿងប្រើប្រាស់ក្នុងផ្ទះនិងប្រដាប់សម្រាប់តែងផ្ទះ គួរតែជូតលាងសំអាតនិងដាក់ឲ្យមានរបៀបរៀបរយ ទីដំណេកក៏គោង១សប្តាហ៍ផ្លាស់គក់បោកលាងហាលថ្ងៃ ។ ពងកាយរបស់យើងក៏១សប្តាហ៍ងូតទឹកដុសញើសក្អែល កុំឲ្យចាប់ស្រមតនិងពងកាយបាន ដើម្បីកុំឲ្យមេជម្ងឺផ្សេងៗ ទ្រានចូលមកញាំញីពងកាយបាន ។ មាត់ជាចំណែក ១ របស់ពងកាយ ត្រូវតែប្រយ័ត្នកុំឲ្យស្មោគគ្រោកបាន ដែលអាចឲ្យកើតៈ ពាសដល់ធ្មេញនិងចំពុកធ្មេញ ហេតុដល់តរយៈជាគ្រឿងរំលាយអាហារ ។

**ការសំអាតមេរោគ.** — ការសំអាតបែបនេះ ជាការសំអាតដោយភ្នែកពុំឃើញ អ្នកដែលធ្វើការសំអាតដោយភ្នែកមើលឃើញនោះ ទើបមិនសំដៅសេចក្តីដល់ការសំអាតបែបក្រោយនេះទេ ។ តាមដោយពិតនោះ មេជម្ងឺផ្សេងៗ តែងមាននៅពាសពេញទួទៅ ដូចជាអាកាសនៅជុំវិញខ្លួនយើងនេះដែរ សុទ្ធមានប្រភេទផ្សេងៗគ្នា ច្រើនលើសលុបគណនា ទាំងចំពួកដែលមើលឃើញដោយកែវឆ្លុះ ទាំងចំពួកដែលមិនអាចត្រូវមើលឃើញបាន ។ ឯក្កុបុលិន្ទ្រីយ៍ដែលមើលឃើញទាំងភ្នែកជាចំពួកមានអំណាចដល់ពងកាយមនុស្សយើង អាចចែងចេញជាប្រភេទមាន ៤ ចំពួក គឺ:

១ - ចំពូកដែលមានគុណដល់កងកាយ ។

២ - ចំពូកដែលតាំងខ្លួនជាកណ្តាលនឹងកងកាយ (គឺឥតគុណឥតទោស) ។

៣ - ចំពូកដែលឲ្យទោសយ៉ាងខ្លាំង ឬឲ្យទោសតែក្នុងឱកាសខ្លះប៉ុណ្ណោះ ។

៤ - ចំពូកដែលឲ្យទោសយ៉ាងខ្លាំង មិនកំណត់ថាទៅឱកាសណា ឬពេលណាទេ ។

មេចុលិទ្រីយ៍ប្ដូរមកម្ដងទាំង៤ចំពូកនេះ យើងឃើញហើយថា មានតែចំពូកមួយប៉ុណ្ណោះ ដែលជាសត្រូវដ៏សាហាវបំផុតដល់កងកាយ គឺចំពូកទី ៤ ។ យើងលវិលត្រឡប់ទៅការមើល ត្រង់កន្លែងដែលនិយាយអំពីគ្រឿងលោមពេលនៅជុំវិញយើងបន្តិចចុះ យើងនឹងឃើញសេចក្តីសំខាន់ម្យ៉ាងក្នុងផ្នែកនោះថា កងកាយរបស់យើង មិនមែនគ្រាន់តែធ្វើការជួសជុលតែមួយមុខទេ គឺបានធ្វើការកែប្រែខ្លួនរក្សាទុកខ្ជាប់ខ្ជួនដល់ជីវិត ដែលត្រូវតែប្រព្រឹត្តទៅតាមសេចក្តីប្រែប្រួលនៃកាលសម័យ ។ សេចក្តីសំខាន់នេះ កាលបើមកប្រៀបគ្នានឹងសេចក្តីដែលថា មេចុលិទ្រីយ៍រមែងមានសាយភាយទៅពាសពេញឥតចន្លោះ ក៏ល្មមមើលឃើញ ព្រានៗថាកងកាយយើងចៀសពន់ពីទឹកដីអាកាសមិនបានយ៉ាងណា កងកាយក៏មិនអាចចៀសរួចពីមេចុលិទ្រីយ៍ផ្សេងៗ បានដូច្នោះដែរ ។

ប្រសិនបើការពារបានក៏ត្រឹមមួយខណៈប៉ុណ្ណោះ ហើយប្រែត្រឡប់ជាជួបប្រទះនឹងមេជម្ងឺផ្សេងៗជាមិនខាន ។

សន្មតថា នាយ ក. ជាអ្នកកាន់ច្បាប់សុខវិទ្យាយ៉ាងម៉ឺងម៉ាត់ មិនព្រមផឹកទឹកដោះគោឆៅ ផឹកតែទឹកដែលដាំពុះជាមុន មិនព្រមស៊ីអាហារស្រស់ ឬឆៅ ដែលឥតកាន់ស្ងោរស្រុះឬលាងដោយទឹកថ្នាំជាមុនដល់ម្ហូបនោះ មិនធ្លាប់ប៉ះពាល់វត្ថុមិនស្អាត ឬបើបួនជាប៉ះពាល់ឬប្រលាក់ក៏លាងឲ្យស្អាត ១ រំពេច សំពត់ការស្លៀកពាក់ក៏ស្អាតបាតជានិច្ច មិនឲ្យស្មោគគ្រោកសៅហ្មងឡើយ ។ ចំណែកខាងនាយ ខ. ប្រតិបត្តិខ្លួនទៅតាមលក្ខណៈម្យ៉ាងគឺប្រកាន់ការសំអាតតែល្មមសមគួរ តាមធម្មតា គេចូលចិត្តផឹកទឹកឆៅ បរិភោគអាហារស្រស់ខ្លះឆ្អិនខ្លះ មិនរអៀសខ្ពើមគ្រឿងស្មោគគ្រោក ចូលចិត្តធ្វើការជាខ្ចាចគ្រប់យ៉ាង ។ ដល់មកក្នុងថ្ងៃមួយ អ្នកទាំងពីរកើតរោគដូចគ្នា សន្មតថា កើតរោគរុះឈក នាយ ក. គោងមានអាការរោគយ៉ាងខ្លាំង ឯ នាយ ខ. មិនសូវជាខ្លាំងក្លាប៉ុន្មានទេ ។

ចុះហេតុអ្វី បានជាអាការរោគនៃជនទាំងពីរនេះទើបខុសពីគ្នាឆ្ងាយ ? មានសេចក្តីអធិប្បាយថា ព្រោះហេតុនាយ ក. មិនព្រមឲ្យរាងកាយបានជួបប្រទះនឹងបុលិន្ទ្រិយ៍នោះឡើយ ស្រាប់តែបានជួបប្រទះនឹងមេជម្ងឺជាដំបូងដែល ចំធ្វើក្តុកជាទម្ងន់តែម្តង, ព្រោះរាងកាយមិនស្គាល់បុទ្ធិគំណាបរបស់បុលិន្ទ្រិយ៍ មិនបេះការពារខ្លួនតាមទំនងដ៏សមគួរ ។

ចំណែកខាងនាយ ។. ពងកាយរបស់គេធ្លាប់ជួបប្រទះនឹងមេជម្ងឺផ្សេងៗ ហើយពងកាយនេះស៊ាំនឹងគ្រឿងការពារមេជម្ងឺអស់នោះ ។ ទើបពងកាយរបស់គេមានអាការរឹងប៉ឹងមិនញាប់ញ័រខ្លាំង ជួយទប់ទល់លៃលកការជួនឲ្យទៅជាស្រាលបាន ។ ការដែលគ្រូពេទ្យរកព្យាបាលប្រភេទខ្លះបានសះជាដុតដាច់នោះ ច្រើនតែមកអំពីអ្នកជម្ងឺមានពងកាយមាំមួនល្អ បន្ទាប់មកគឺការដាក់ថ្នាំជម្រុះនឹងពេលហ្នឹងឯង ទើបធ្វើឲ្យកំឡាំងពងកាយកាន់តែមានកំឡាំង តទល់នឹងពងកាយខ្លាំងឡើងទៀត មិនមែនដោយអំណាចថ្នាំតែម្យ៉ាងទេ ។ ឯកំឡាំងទប់ទល់របស់ពងកាយនេះ ក៏គឺការប្រែប្រួលក្នុងខ្លួនយើងដែលកើតមានពីការទទួលសម្ផស្សប៉ះពាល់ នឹងគ្រឿងបោមពេមនៅជុំវិញខ្លួនយើងហ្នឹងឯង ។

(សេចក្ដីដែលថ្លែងមកនេះ ជាយោបល់មួយដោយឡែករបស់គ្រូពេទ្យអ្នកតែងគម្រោងនារីវេជ្ជសាស្ត្រនេះ មិនបាច់ស្របឬមិនស្របនឹងយោបល់របស់គ្រូពេទ្យដទៃៗទេ) ។

ការថែនប្រភេទមេពុលទ្រីយ៍ ត្រង់ពីរបំពួកដំបូងនោះយើងមិនបាច់ព្រួយបារម្ភឡើយ ។ ម៉ពកនេះយើងតែងបានជួបប្រទះក្នុងអាហារស្រស់ ដែលមិនទាន់បានដុតឬស្ងោរជាមុន នៅក្នុងដី ក្នុងទឹក ក្នុងអាកាស ទីងក្នុងពងកាយយើងក៏មាន ដូចក្នុងមាត់, ក, ប្រមុះ ក្នុងពោះវៀនធំ ក្នុងទ្វារប្រស្សាវនឹងតាមពងកាយខាងក្រៅរបស់យើងផង ។ ឯបំពួក

ទី ៣ នោះជាចំពូកមាននៅខួរក្បាលសត្វអន្ទើ ជ្រាបមកដល់ក្នុងខ្លួនយើង តែ ជារាងកាយយើងបង្កមិត្រមេត្រីមិនឲ្យចាស់ហែង តាំងការពារមិនឲ្យបៀត បៀនរាងកាយបានផង មេរោគចំពូកនេះ ទើបយើងមិនបាច់ចៀសវាង ឡើយ ។

ឯមេបុលិន្ទ្រិយ៍ពួកទី ៤ ជាចំពូកដែលរាងកាយយើងត្រូវនឹងចង មិត្រមេត្រីបានសម្រេច តែមេរោគនេះ ធម្មជាតិមិនបានផ្សាយឲ្យមាន សុះសាយខ្លួនទៅទេ វាមាននៅដោយអន្ទើដោយទុកសន្ទះប៉ុណ្ណោះ ។ មេរោគរបេង គាបមានខ្លួនទៅតាមល្អងធូលី សូម្បីក្នុងទឹកស្រះតែមិនមាន ពន្លឺថ្ងៃកំដៅក៏មានមេរោគចំពូកនេះដែរ តែដោយហេតុនោះ វាចូលចិត្តនៅទីងងឹតណាមួយ ក្នុងរាងកាយរបស់យើង ឯគោល សំខាន់បំផុត គឺថាបើរាងកាយមិនខ្សោយកំឡាំងពេក ដែលជាកន្លែង ដីជាតិដីមានទុជាសេហើយ មេរោគចំពូកនេះក៏ស្រ័យនៅពុំបាន ឡើយ ។ ឯមេកាមរោគផ្សេងៗ គាស្រ័យនៅបានតែទីងរាងកាយ របស់យើងប៉ុណ្ណោះ ហើយបំឡងគ្នាបានដោយគម្រ វៀរលែងតែរួម ដំណេកជាមួយគ្នា ។ មេជម្ងឺមូលសំពោរ-ឈាម មេរោគអស់នេះ តាមធម្មតា មិនស្ញូវទ្ធើកលេងលខ្លាំងប៉ុន្មានទេ ដែលខ្ជូនទៅបាន ដោយសារបានទទួលមេរោគ ។ មេជម្ងឺពីរក្នុងដែលកំពុងកើតរោគទេប្ដូ ពីទឹកឬអាហារចំណីដែលមានមេរោគប្រកបនេះ តែថាបើមានការថែ

ហេតុតាំងការ ក៏មិនឲ្យទោសខ្លាំងប៉ុន្មានដែរ ដូចរោគមួយសំរាប់ថ្ន
ណាមនោះ អាចសះជាបានដោយងាយ ។ មេជម្ងឺអាសន្នរោគ ប្រសិន
បើមិនមែនជាសម័យកើតពាសពេញទេ ស្ទើរតែមិនមានជម្ងឺពួកនេះ
ឬបើមានក៏មានតែបន្តិចបន្តួចប៉ុណ្ណោះ មេជម្ងឺពួកនេះ មាននៅតែក្នុង
អាហារទឹកដីប៉ុណ្ណោះ ឬនៅក្នុងលាមករបស់អ្នកជម្ងឺដោយរោគនេះ
ចំពោះអ្នកដែលមានកំឡាំងកាយពូកែ រោគពួកនេះ មិនធ្វើឲ្យធុន
ជាប៉ុន្មានឡើយ ។ មេរោគព្រួសក្តាយក៏មានចំនួនជាច្រើនដែរនៅក្នុង
ណា ដែលអត់ពន្លឺថ្ងៃចាំងចូលទៅដល់ ដូចក្នុងអាចម៍ផោកាចម៍ក្របី
ក្នុងស៊ីចដែកគោល តែមេរោគពួកនេះធ្វើអន្តរាយដល់កនិកាយបាន
លុះតែកនិកាយមានរបួសបើកផ្លូវឲ្យវាចូលទៅបាន ហើយដំបៅនេះបិទមុខ
ជិតអត់ពន្លឺថ្ងៃ ឬអាកាសចូលទៅដល់ខាងក្នុងដំបៅនេះ ទើបមេរោគ
កើតឡើងយ៉ាងរហ័ស ប្រសិនបើមុខដំបៅនេះបានលាងសំអាតល្អហើយ
មេរោគនេះក៏ស្លាប់អស់ទៅជាមិនខាន ។ មេជម្ងឺគ្រុនញាក់ ជាមេរោគ
មានជីវិតរស់នៅបានតែក្នុងក្រពះមូស ១ ពួក បើមិនមានមូសពួកនេះ
ឬបើយើងមិនត្រូវមូសពួកនេះខាំទេ យើងក៏មិនកើតរោគគ្រុនញាក់
នេះសោះឡើយ ។ ក្រៅពីរោគដែលបានបញ្ចេញឈ្មោះមកនេះ នៅ
មានរោគដទៃទៀតជាច្រើន ហើយឲ្យទោសពិតច្រើនតាមទំនងដែល
រៀបរាប់មកនេះ ។ មានសេចក្ដីសំខាន់មួយយ៉ាងទៀត គឺថាយើងអាច

ការពាររោគអស់នេះបាន បើយើងយកចិត្តទុកដាក់រៀនចំណេះបង្ការរោគទុកខ្លះ ។ កាលបើដឹងថា វេលានេះរដូវនេះកំពុងមានរោគចូលបំពួកនេះ តាមទំនងតាមចំណីអាហារ យើងត្រូវតែប្រយ័ត្នរក្សាសំអាតរបស់អស់នេះឲ្យហ្មត់ចត់ ទំរាំស្ងប់ស្ងាត់បាត់ទៅវិញ ។ យើងដឹងថា មុខរបួសដំបៅជាទ្វារចូលនៃមេរោគ យើងត្រូវតែរក្សាសំអាតមុខរបួសដំបៅទំរាំតែជាស្រឡះ ។ ប្រសិនបើបេះវិធីបង្ការនិងការរក្សាដាក់បញ្ជាស់ហើយ យើងមិនបាច់មានសេចក្ដីព្រួយបារម្ភឡើយ ។

យើងគួររក្សាការសំអាតដូនខ្លួនរបស់យើងឲ្យល្អ ដើម្បីឲ្យបានសុខកាយសុខចិត្ត តែកុំបង្ហើការសំអាតហួសទៅ ដើម្បីប្រាសចាកចុលក្រៃយ៍ ប្រហែលនឹងការសំអាតខ្លួននេះឡើយកុំប្រព្រឹត្តហួសទៅត្រូវតែបរិភោគអាហារឆ្អិនក្ដៅគ្រប់មុខគ្រប់ប្រការពេក កុំប្រយ័ត្នហួសមិនព្រមផឹកទឹកក្ដៅទឹកត្រជាក់ ។ កុំប្រយ័ត្នហួសមិនព្រមប៉ះពាល់គ្រឿងស្មោកគ្រោកមិនឲ្យប្រឡាក់ខ្លួនសោះឡើយ ហើយកុំប្រយ័ត្នពាល់តែឃើញអ្នកដទៃមានសេចក្ដីរង្កៀសហួសគេ ដែលគេមិនបានសំអាតស្មើនឹងខ្លួន ។ ប្រសិនបើយើងប្រតិបត្តិហួសថ្នាក់នេះ មុខជាជីវិតយើងមិនបានរបសាស្រួលឡើយ ហើយចួនជាប៉ះពាល់នឹងមេជម្ងឺ មុខជាកើតទោសដល់កងកាយជាខ្លាំងមិនខាន ។ កងលោកនេះ មិនមានអ្នកណាមួយចៀសរួចពីចុលក្រៃយ៍ផ្សេងៗ បានឡើយ ។ ការដែលយើងត្រូវប្រយ័ត្នហួសថ្នាក់នេះ លុះតែមានហេតុគេខុសពីប្រក្រតីកើតឡើងប៉ុណ្ណោះ ។

មុននឹងបញ្ចប់វគ្គនេះ លោកអ្នកនឹងបានសុំឲ្យអស់លោកអ្នកមើលសេចក្ដីនេះ ឆ្ពោះទៅពិចារណាមើលកងកាយ របស់អ្នកស្រែចំការរបស់យើងចន្ទិចចុះ ជនពួកនេះ នៅឆ្ងាយពីតំបន់ដែលមានសេចក្ដីចំរើនរុងរឿង ដែលមានគលៗឆ្ងាយពោកប្រាសនានាប្រការ អ្នកស្រែចំការអស់នោះ មិនសូវមានទុក្ខសោកទៅមកកាន់ក្រុង លម្មឲ្យជាទីស្និទ្ធស្នាលនឹងអ្នកក្រុងនឹងគេ ហើយពួកអ្នកក្រុងជាច្រើន សំឡឹងឃើញបងប្អូនពួកនេះជាគតាបសោកគ្រោក មិនសុីវិល័យដូចខ្លួន ។ តែតាមដោយសេចក្ដីពិតជនចំពួកនេះ បានរស់នៅរួមនឹងធម្មជាតិ គ្រាន់តែមានខ្ទមឬផ្ទះសំរាប់ជ្រកភ្លៀងនឹងកំដៅ នឹងអាស្រ័យដេក ចិញ្ចឹមជីវិតដោយការងារដែលត្រូវប្រើកំឡាំងកាយក្រោមកំដៅថ្ងៃនឹងភ្លៀងលៃងឲ្យខ្លួនប្រាណប្រ-ឡាក់ប្រឡូសដោយធូលីអាចម៍ដី នឹងកក់ល្បាប់ផ្សេងៗ បើទុកជាមានការសំរាកខ្លះ គឺចំពោះការដើរមើលបុណ្យឬដើរលេងកំសាន្ត ឬពេលចូលដំណេកប៉ុណ្ណោះ ឯទឹកប្រើកន្ទូរ, ព្រែក ប្រឡាយសោតទៀត ក៏ច្រើនតែល្អក់កករ ទឹកនេះហើយសម្រាប់ជម្រះលាងកងកាយរបស់គេ គ្រាឃ្លានក៏បរិភោគ គ្រាឈឺពោះបត់ជើងក៏ទៅបត់ជើងភ្លាមមិនបង្អង់ វេលាទំនេរពីការងារ ក៏សប្បាយហ៊ឺហាសើចលេងកំសាន្តទៅ ដល់ពេលព្រលប់ក៏នាំគ្នាចូលដំណេក មិនដើរលេងយប់មើលកុនល្ខោនឲ្យអត់ងងុយដូចអ្នកក្រុងទេ ហើយមិនសូវតែងលំគ្នាសារប្រើគំនិតប៉ុន្មានឡើយ ។

ពួកអ្នកជនបទអស់នេះយើងនឹងឃើញថា គេមានទឹកមុខនិងសាច់ខ្មៅក្រៀមដោយកំដៅថ្ងៃនិងខ្យល់ មានដៃគ្រោតគ្រើមមិនទន់ភ្លន់-សាច់មិនស្រោយដូចអ្នកក្រុងទេ ទើបយើងឃើញថា ពួកអ្នកជនបទអស់នោះមានទឹកមុខនិងសាច់ឈាមមិនដាច់ស្រពោនសោះឡើយ តែជនពួកនេះជាអ្នកប្រតិបត្តិតាមសេចក្តីត្រូវការរបស់ធម្មជាតិយ៉ាងមុឺងម៉ាត់ ទើបមិនសូវមានជម្ងឺដំកាត់ច្រើនពេក ដូចពួកជនដែលប្រះប្រៀតប្រជែកគ្នានោះ ។ ចុះជាអ្នកជនបទខេត្តក្រៅ មានកំឡាំងកាយរឹងប៉ឹងមាំមួន ហើយមានសេចក្តីអត់ធន់ច្រើនជាងពួកអ្នកក្រុងក៏ពិតមែន តែនៅមានការខ្វះខាតហេតុ ២ ប្រការទៀត ដែលជាបច្ច័យនាំឲ្យបានសុខកាយសុខចិត្តនិងអាយុយឺន គឺប្រការទី ១ អាហារ សេចក្តីទាល់ក្រនិងការមិនចេះច្បាប់សុខាភិបាល នាំឲ្យជនពួកនេះបានបរិភោគអាហារស្រស់ល្អឲ្យល្មមនឹងសេចក្តីត្រូវការរបស់រាងកាយ ។ ប្រការទី ២ គឺពេទ្យវេលាមានជម្ងឺឈឺចាប់ ជនពួកនេះ មិនសូវមានការព្យាបាលត្រឹមត្រូវតាមវិជ្ជាពេទ្យឡើយ ច្រើនដូចប្រទះតែថ្នាំបែបបុរាណ ទំនេរក្បាដោយមន្តអាគមឬអារក្ស អ្នកតាដែលសះជាចាក់ពេកនៅបាន ដោយអំណាចរាងកាយរបស់គេ មានកំឡាំងតទល់នឹងរោគយ៉ាងមាំមួន ។ ការប្រសូតបុត្រតាមជនបទខេត្តក្រៅសោតទៀត ក៏មុខគួរឲ្យស្រៀវស្រើបអន្តរាយណាស់ដែរ ប៉ុន្តែនៅកាលតទៅមុខទៀត វិជ្ជាពេទ្យចំរើនឡើងសាយភាយទូ

ទៅដល់ជនបទខេត្តក្រៅផង ហើយអ្នកស្រែ-ចំការរស់នោះ ចេះវិធីបង្ការរោគដោយខ្លួនឯងផង ទើបនាំឲ្យពលកាយរបស់គេ ប្រកបដោយកំឡាំងរឹងប៉ឹងនិងអាយុយឺនយូរ មានសេចក្តីសុខសប្បាយតាមធម្មជាតិនៃសង្ខារពលកាយរបស់មនុស្សជាប្រាកដពុំខាន ។

ចប់

---

ឃុនសុន្ទរមេធី ញ៉ង-សឿង ប្រែ

លោក ហង់-គឹមសេង ពិនិត្យ

(តមក)

---

តាមខ្ញុំយល់ឃើញ បងត្រូវតែចែកចាយទ្រព្យសម្បត្តិរបស់ខ្លួន ដល់កូនស្រីខ្លួន ខ្ញុំថាដូច្នេះ តើមិនសមរម្យយ៉ាងណា ? ។

សូម្បីនូវេទឌិន-អលី និយាយពាក្យនេះទាំងសើចញញឹមផង ប៉ុន្តែបងនោះជាអ្នកមានចិត្តស្រាលពេក ក៏ត្រឡប់ជាកាក់អន់ចិត្តនឹងប្អូនរបស់ខ្លួន ទើបនិយាយឡើងដោយកំហឹងថា "កូនប្រុសរបស់ឯងមានគ្រោះធំហើយ ព្រោះឯងហ៊ានយកមកផ្ដុំនឹងកូនស្រីអញ ! អញស្គាល់ឃើញថា ឯងជាមនុស្សព្រហើនកោងកាចហ៊ានមើលងាយកូនស្រីអញ គិតឲ្យអញលើកឲ្យទៅកូនប្រុសឯងទទេៗ, មិនមែនងាយដូចជាសេចក្ដីប៉ុនប៉ងរបស់ឯងទេ កុំថាតែត្រឹមប៉ុណ្ណោះ ទោះបីឯងជូនសម្បុរសម្បត្តិឲ្យច្រើនកើនហួសពីឯងមានទៅទៀត ក៏អញមិនឲ្យដែរ" ។ ការជជែកប្រកែកគ្នាលេងរវាងបងប្អូនទាំងពីរនាក់ចំពោះអាពាហ៍ពិពាហ៍ នៃកូនប្រុសស្រីរបស់ខ្លួនដែលមិនទាន់ទាំងកើតមកផងនោះ នាំឲ្យមានរឿងជាប់តរៀងឆ្ងាយទៅទៀត ។ ចំណែកខាងសេមសេទឌិន ម៉ូហាម្មេទ ទេវទឹង

ហេតុដល់បងគំនុំគុំគួន ហើយក៏និយាយតាមប្អូនថា "ថ្ងៃស្អែកនេះទាស់តែអញមានកិច្ចរវល់ជូនព្រះរាជដំណើរស្តេចទៅប្រពាតព្រៃទេ កុំអីអញនឹងធ្វើបាបឯងឲ្យសមតាមចិត្តម្ដងមើល ប៉ុន្តែមិនអីទេ. ចាំដល់ត្រឡប់មកវិញអញនឹងធ្វើឲ្យឯងដឹងអំពីរឿងដែលប្អូនហ៊ានប្រមាថមើលងាយបង" ។ កាលនិយាយដូច្នេះហើយ បងនោះចូលទៅក្នុងបន្ទប់ខ្លួនបាត់ទៅ, ចំណែកទ ងប្អូនក៏ទៅដេកក្នុងបន្ទប់គាត់ដែរ ។

លុះដល់ថ្ងៃស្អែកឡើងពេលព្រលឹមស្រាងៗ សេមសេទ.ឌិនម៉ូហ-ម្មេទ ក្រោកឡើងហើយចូលក្នុងព្រះរាជវាំង ចេញទៅជាមួយនឹងព្រះរាជាធ្វើដំណើរតាមផ្លូវវាងលើក្រុងកៃរ៍ ក្បែរបេតិយអនុស្សាវរីយ៍ដើម្បីប្រពាតព្រៃ ។ ចំណែកខាងនូរេទឌិន-អលី ដេកសញ្ចប់សញ្ចឹងសង្ងឹងសង្ងៃព្រួយព្រួយណាក្នុងវេលាព្រឹកនោះឯង ហើយនឹកពិចារណាសព្វៗ ទៅឃើញថា នឹងនៅរួមសុខរួមទុក្ខជាមួយនឹងបងឲ្យយូរយារតទៅទៀតពុំបានឡើយ គោងតែគេបណ្ដេញទៅឲ្យផុតអំពីទីនេះ ព្រោះគេគាត់អន់ហេតុដល់បងគំនុំគុំគួនទៅហើយ, លុះគិតឃើញដូច្នេះហើយទើបរៀបចំអីវ៉ាន់ផ្សេងៗមានទាំងការុងមាសពេជ្រ នឹងស្បៀងអាហារផងដាក់ផ្ទុកលើខ្នងលាមួយ ហើយនិយាយផ្ដែផ្ដាំនឹងបាវព្រាវក្នុងផ្ទះថា ខ្លួនត្រូវការធ្វើដំណើរទៅខាងក្រៅក្រុងប្រហែលជាពីរ-បីថ្ងៃ រួចហើយក៏ជិះលាចេញទៅតែម្នាក់ឯង ។

លោកឌូរេទឌិន-គលី កាលចេញទៅដល់ខាងក្រៅក្រុងកៃរហើយ ទើបជិះលោបរកាត់ផ្លូវឆ្ងាយដាច់ស្រយាល ព្រោះទៅកាន់ប្រទេសអាព៊ីប ។ ប៉ុន្តែដោយផ្លូវនោះវែងឆ្ងាយពេក លាដែលជាពាហនៈនោះក៏ស្លាប់ត្រង់កណ្តាលផ្លូវនោះទៅ, ឌូរេទឌិន-គលី ខំទ្រាំស្ពាយអីវ៉ាន់ដើរទៅ ដោយដើរមុខគួរឲ្យកំសត់ខ្លួនពន់ពេក ។ ដោយអំពើសំណាងល្អណាស់ មានអ្នករទេះរត់សំបុត្រម្នាក់មានដំណើរទៅកាន់ក្រុងបាល់ស្គ៉ូ បានប្រទះឃើញលោកត្រង់ពាក់កណ្តាលផ្លូវ ហើយក៏ឲ្យលោកជិះពីខាងក្រោយ ធ្វើដំណើរតទៅទៀត ។ កាលបុរសអ្នកបររទេះនោះបានទៅដល់ក្រុងបាល់ស្គ៉ូហើយ លោកឌូរេទឌិន-គលី ក៏ថ្លែងសេចក្តីអរគុណជាទីបំផុត ដោយបានជួយចំឡងលោកអំពីផ្លូវឆ្ងាយដាច់ស្រយាល រួចហើយលោកដើរទៅតាមផ្លូវថ្នល់ដើម្បីស៊ើបសួររកកន្លែងសំណាក់ ស្រាប់តែឃើញមន្ត្រីជាន់ខ្ពស់ម្នាក់ដើរមកជិត មានទាំងមនុស្សជាច្រើនដើរជូនដំណើរតាមក្រោយផង ហើយពួកមហាជនអ្នកដើរតាមផ្លូវនាំគ្នាឈប់គំនាប់គាប់គួរយ៉ាងលំអុតលំឱន ដរាបដល់មន្ត្រីនោះដើរហួសផុតទៅ ។ ចំណែកខាងលោកឌូរេទឌិន-គលី ក៏ឈប់គំនាប់គួរសមដូចជាអ្នកឯទៀតដែរ, មន្ត្រីជាន់ខ្ពស់នោះគឺជាអគ្គមហាលេខានៃព្រះរាជាក្រុងបាល់ស្គ៉ូ, លោកដើរក្នុងទីក្រុងដើម្បីត្រួតត្រាមើលរបៀបរៀបរយ និងសេចក្តីសាន្តត្រាណរបស់បណ្តារាស្ត្រ ។

សេនាបតីនោះ ពោលក្នុងចំពោះមនុស្សក្រឡោះ ឌូវេឌិន-អលី ឃើញទម្រង់មុខមាត់ល្អស្រស់ប្រិមប្រិយ គួរឲ្យពិតពិលរមិលមើល ទើបលោកសំឡឹងហើយសំឡឹងទៀតដោយសេចក្ដីពេញចិត្ត ។ អគ្គមហា-សេនាដើរចូលទៅជិត ឃើញសំលៀកបំពាក់ជារបៀបអ្នកដំណើរលោកក៏ឈប់សាកសួរដំណើរដើមទងសព្វគ្រប់ ។ ឌូវេឌិន-អលី ជំរាបតាមត្រង់ថា "សូមជំរាបប្រសាសន៍លោក, ខ្ញុំបាទនៅស្រុកអេស៊ីប្ត៍, កើតនៅក្រុងកែរ៍, ឯដំណើរដែលខ្ញុំបាទដើរចោលស្រុកកំណើតមកក្នុងទីនេះ ព្រោះមានសេចក្ដីអាក់អន់ចិត្តនឹងបងម្នាក់ ហេតុដូច្នេះបានជាខ្ញុំបាទដើរផ្ដេសផ្ដាសទៅកាន់លោកទាំងមូល ដោយបំណងថាសូម្បីស្លាប់ទៅចុះ ប្រសើរជាជាងការវិលត្រឡប់ទៅវិញ" ។ លោកអគ្គមហាសេនា ជាមនុស្សចាស់ទុំគួរគោរព កាលបានឮពាក្យនោះហើយ ក៏ពោលថា "កូនប្រុសឯពុក, គំនិតរបស់អ្នកបែបនេះមិនត្រូវសោះ ព្រោះក្នុងលោកទាំងមូល មានសុទ្ធតែសេចក្ដីទុក្ខលំបាកផ្សេងៗ បំណែករូបអ្នកមិនដឹងថាសេចក្ដីទុក្ខលំបាកនោះ នឹងមកប៉ះពាល់ដល់ខ្លួនក្នុងកាលណាទេ, ណ្ហើយចូរអ្នកទៅតាមខ្ញុំឥឡូវនេះចុះ ប្រហែលជាខ្ញុំនឹងធ្វើអ្នកឲ្យភ្លេចដើមចមដែលនាំបណ្ដាលឲ្យអ្នកដើរចោលស្រុកមកនេះ ។

ឌូវេឌិន អលី ក៏ដើរទៅតាមលោកអគ្គមហាសេនាក្រុងបាល់ស៊ូរ៉ា ហូតទៅដល់ផ្ទះហើយនៅអាស្រ័យផ្ទាំសុខសប្បាយក្នុងទីនោះ; កាល

លោកអគ្គមហាសេនាបានស្គាល់កិរិយាមារយាទសណ្ដាប់ធ្នាប់ល្អរបស់នូវទេវឌិន-អស៊ីហើយ លោកក៏មានសេចក្ដីស្រឡាញ់ពេញចិត្ត ទុកដូចជាកូនបង្កើត, ក្នុងសម័យថ្ងៃមួយបេកំពុងដើរដេតគ្នាលេងតែពីរនាក់ លោកមានប្រសាសន៍ចំពោះនូវទេវឌិន-អស៊ីថា "កូនប្រុសឪពុក, ខ្លួនយើងនេះដូចអ្នកឃើញស្រាប់ គឺចាស់តែចាស់ត្រាំត្រាណាស់ហើយ, តាមស្មានមើលទៅយើងមិនបានជាសៅនៅយូរប៉ុន្មានទៀតទេ ។ ទេព្ដាបានដាក់ពានកូនស្រីតែមួយឲ្យយើង, នាងមានរូបឆោមក៏ល្មមគួរសមហើយសព្វថ្ងៃនេះមានអាយុកំពុងពេញការ ពួកនាហ៊ឺនសព្វមុខមន្ត្រីនិងសេដ្ឋីគហបតីជាច្រើនគ្នានៅក្នុងក្រុងនេះ បានមកនិយាយដណ្ដឹងឲ្យកូនប្រុសរបស់គេអស់កាលជាច្រើនដងណាស់ហើយ, ប៉ុន្តែយើងមិនព្រមឲ្យសោះ ។ ចំពោះរូបបាឯងវិញ; យើងមានសេចក្ដីស្រឡាញ់ដោយស្មោះត្រង់ ហើយយល់ឃើញថាគួរនឹងចងភ្ជាប់ជាញាតិពន្ធទៅវិញទៅមក គឺយើងយល់ព្រមទទួលយកបាឯងធ្វើជាកូនប្រសាបាន, ប្រសិនបើបាយល់ព្រមស្មោះស្ម័គ្រ ដោយសេចក្ដីពេញចិត្តតាមបំណងរបស់យើងនេះ យើងនឹងចូលទៅក្រាបទូលព្រះរាជាដើម្បីនឹងរៀបចំធ្វើអាពាហ៍ពិពាហ៍ ហើយយើងនឹងសូមព្រះរាជានុញ្ញាតឲ្យទ្រង់ផ្លាស់ប្ដូរឋានន្តររបស់យើងជាអគ្គមហាសេនាសព្វថ្ងៃនេះទៅឲ្យអ្នកវិញ, យើងនឹងឈប់សម្រាកខ្លួនក្នុងបច្ឆិមវ័យហើយចូរអ្នកជឿជាក់ប្រាកដចុះថា យើង

មិនមែនប្រគល់ឲ្យតែទ្រព្យសម្បត្តិកេរ្តិ៍មត៌កតែប៉ុណ្ណោះទេ ទោះទាំងកិច្ចការពារការគ្រងនគរទាំងមូលនេះ ក៏យើងប្រគល់ដាច់មុខឲ្យអ្នកកាន់កាប់ត្រួតត្រាទាំងអស់" ។

លោកអគ្គមហាសេនាក្រុងបាល់ស្ទូក៏ និយាយពាក្យដ៏ប្រកបដោយសេចក្តីសប្បុរសសន្ដោសប្រោសប្រាណនេះមិនទាន់ទាំងចប់សព្វគ្រប់ផង ឧបរេទខិន-អលី ក៏លុតជង្គង់ក្រាបចុះទៀបជើងរបស់លោកដើម្បីសំដែងសេចក្តីត្រេកអរនិងសេចក្តីដឹងគុណជាអនេក ចំពោះលោកដែលមានចិត្តសប្បុរសយ៉ាងនេះឯង ហើយបានទទួលព្រមតាមសេចក្តីផ្ដួងនោះដោយអំណរយ៉ាងក្រៃលែង ។ គ្រានោះ អគ្គមហាសេនាហៅមេទាហានធំៗដែលនៅប្រចាំសម្រាប់ផ្ទះលោក ឲ្យមកជួបជុំគ្នាហើយបង្គាប់ឲ្យរៀបតាក់តែងបន្ទប់ធំនៃភោជនាគារ (ផ្ទះស៊ីលៀង) របស់លោក ព្រមទាំងឲ្យតាក់តែងគ្រឿងភោជនីយាហារនិងខាទនីយាហារ យ៉ាងថ្កុំថ្កើងសម្រាប់ទទួលភ្ញៀវរួចហើយ លោកឲ្យទៅអញ្ជើញអស់ព្រះរាជវង្សានុវង្សនាហ្មឺនសព្វមុខមន្ត្រីនិងពួកសេដ្ឋីគហបតីក្នុងទីក្រុងនោះទាំងអស់ សូមឲ្យអញ្ជើញមកជាមង្គលក្នុងគេហដ្ឋានរបស់លោក ។ កាលដល់កំណត់ពេលវេលា ពួកភ្ញៀវមកជួបជុំគ្នាហើយ, ចំណែកខាងឧបរេទខិន-អលី បានជំរាបបិតាក្មេកឲ្យបានជ្រាបអំពីឋានៈរបស់ខ្លួនជាស្រេចដោយប្រការផ្សេងៗ ។ លោកអគ្គមហាសេនាជាបិតាក្មេក ក៏និយាយប្រកាសប្រាប់

ដល់អស់លោកដែលបានមកសុំដណ្ដឹងកូនស្រីលោកកាលពីជាន់មុន តែលោកប្រកែកមិនព្រមឲ្យនោះ ដើម្បីឲ្យគេបានដឹងគ្រប់គ្នា ដោយពាក្យលុបលាងដោះសាថាដូច្នេះ «អស់លោកអ្នកទាំងឡាយ, ពេលនេះខ្ញុំសូមជំរាបអស់លោក អ្នកឲ្យបានជ្រាបអំពីការសម្ងាត់មួយដែលខ្ញុំបិទបាំងលាក់ទុកមកអស់កាលយូរហើយ ជំរាបដល់ថ្ងៃនេះឯង គឺ: ខ្ញុំមានបងប្រុសម្នាក់ធ្វើជាឧត្ដមមហាសេនានៃព្រះរាជាប្រទេសអេស៊ីព្ទ ដូចជាខ្ញុំដែលមាននាទីជាឧត្ដមមហាសេនានៃព្រះរាជាក្នុងប្រទេសយើងនេះដែរ បងខ្ញុំនោះមានតែកូនប្រុសមួយ ហើយគាត់មិនពេញចិត្តឲ្យកូនយកប្រពន្ធនៅស្រុកអេស៊ីព្ទនោះសោះ គាត់បានបញ្ជូនកូនប្រុសគាត់មកឲ្យខ្ញុំរៀបចំអាពាហ៍ពិពាហ៍ជាមួយនឹងកូនស្រីខ្ញុំ ដើម្បីនឹងធ្វើសាខាទាំងពីររបស់យើងឲ្យបានមូលត្រកូលជិតស្និទ្ធតទៅទៀត, កូនប្រុសនោះខ្ញុំទើបនឹងបានស្គាល់ជាក់ជាក្មួយខ្ញុំក្នុងវេលាដែលវាមកដល់ ហើយខ្ញុំក៏ព្រមទទួលយកធ្វើជាកូនប្រសាតាមបំណងរបស់បងខ្ញុំ, កូនប្រសានោះគឺឌ្រីកឡោះនេះឯង (លោកបន្ទុលបញ្ហាញ) ដូចអស់លោក-អ្នកបានឃើញស្រាប់ៗ ខ្ញុំសូមឲ្យអស់លោក-អ្នកអញ្ជើញមកជាមង្គល ក្នុងកិច្ចអាពាហ៍ពិពាហ៍ដែលខ្ញុំបានសម្រេចថានឹងរៀបចំធ្វើក្នុងថ្ងៃនេះៗ បណ្ដាពួកនាហ្មឺនធំ-តូចទាំងឡាយនោះ ឥតមានអ្នកណាមួយយល់ទទឹងទាស់ថាដូចម្ដេចឡើយ សុទ្ធសឹងតែឆ្លើយព្រមគ្នាថាដំណើរដែលលោកគិតគូររៀបចំ អាពាហ៍-

ពិពាហ៍នោះជាការប្រពៃណាស់ហើយ ! អ្នកទាំងអស់គ្នាយល់ព្រមអបអរសាទរស្មោះស្ម័គ្រមកជាមន្តលពុំហ៊ានខាន ហើយបានទាំងជូនពរស័ព្ទសាធុការសូមឲ្យព្រះជួយបំរុងបំរើនអស់កាលជាអង្វែងតទៅ ដើម្បីនឹងបានទទួលប្រទះនូវផលប្រយោជន៍ ដែលល្អតណាស់ដុះដាលអំពីការមូលមិត្រនៃវង្សត្រកូលដ៏សុខក្សេមក្សាន្តនេះឯង ។

ពួកនាហ្មឺនមុខមន្ត្រីធំ-តូចទាំងអស់ដែលបានមកជួបជុំគ្នា នៅផ្ទះលោកអគ្គមហាសេនាក្រុងបាល់សូក៏ ក៏មានសេចក្តីរីករាយសប្បាយចំពោះរឿងដែលអគ្គមហាសេនា រៀបចំការកូនស្រីជាមួយនឹងនូវេខឌិន·អលី; ក្នុងពេលនោះ គេចាប់ដើមលៀងភ្ញៀវតាមទំនៀម, ភ្ញៀវទាំងឡាយក៏នៅស៊ីផឹកក្នុងទីនោះអស់កាលយូរណាស់ លុះចប់ភោគភោជនីយាហាររួចហើយ ពួកអ្នកបំរើភ្ញៀវបានលើកខាទនីយាហារ (បង្អែម) មានដំណាប់ផ្សេងៗជាដើមយកមកជូនភ្ញៀវជាកិច្ចបង្ហើយចុងក្រោយ តាមទំនៀមស្រុកភ្ញៀវម្នាក់ៗ តែងវេចខ្ចប់នំបានប៉ុន្មានក៏យកចំណោះទៅផ្ទះ ។ តពីនោះទៅពួកចៅក្រមកាន់សំបុត្រសញ្ញានៃអាពាហ៍ពិពាហ៍ចូលមក ហើយអស់លោកមន្ត្រីជាន់ខ្ពស់ទាំងឡាយ ក៏ចុះហត្ថលេខាជាសាក្សីជួយជំងឿផង រួចហើយក្រុមភ្ញៀវទាំងអស់ជំរាបលាលោកអគ្គមហាសេនា ថយទៅកាន់គេហដ្ឋានរៀងៗខ្លួន ។

(មានត)

## រឿងព្រេង

អ្នកឧកញ៉ាឥស្សរវង្សា ស៊ំ-ស៊ិន រៀបរៀង

# រឿងអាជូជឹង

(តមក និង ចប់)

---

តាជូជកគាត់ក៏ខំខ្នះខ្នែង ស្វែងរកឲ្យនាងបរិភោគបានគ្រប់យ៉ាង ក្រោយមកតាជូជក គាត់ធុញទ្រាន់នឹងការបំរើនាងពុំបាន ដោយប្រាណគាត់ចាស់ តែចាស់កំឡាំងក៏ខ្សោយ ទើបគាត់នឹកដល់ព្រះបាទស្រីវេស្សន្តរមានព្រះរាជបុត្រាបុត្រី ២ ព្រះអង្គនាំចេញទៅនៅឯភ្នំគិរីវង្កត ។ បើអាត្មាអញទៅសុំយកមកឲ្យបំរើនាងអមិត្តតាប្រហែលជាបាន ព្រោះលោកកំពុងបំពេញទានបារមី តាជូជកគិតដូច្នោះហើយ ក៏នៅរង់ចាំតែនាងអមិត្តតាសំរាលកូនរួចទើបចេញយាត្រាទៅសុំព្រះរាជកុមារ មកបំរើនាងអមិត្តតា ។

លុះនាងអមិត្តតាមានគភ៌គ្រប់១២ខែក៏សំរាលកូន (គភ៌នេះវែងណា) ។ ឯតាជូជកគាត់ក៏ស្លុតក្នុងការសំរាលកូន ព្រោះគាត់មានក្បួនខ្នាតពីកេង ដោយគាត់ធ្លាប់ធ្វើជាឆ្មប ១ ដែរ កាលសំរាលចេញគាត់ឃើញជាកូនប្រុស គាត់ក៏នឹកត្រេកអរណាស់ គាត់ទះដៃហើយលោតខ្ទន់ញាប់ញ័រ ទើបលើកលានផុសតក់ស្លុតហើយ គាត់ដាក់ឲ្យដេកក្នុងស្លាបព្រក ហើយលើកដាក់ក្នុងសរ៉ែងកញ្ឆ្រែង បង្ការកុំឲ្យសត្វចឹកខាំ ព្រោះផ្ទះគាត់

មានសង្ហើចកុះករណាស់ លុះកើតបាន ៧ ថ្ងៃ តាជូជកគាត់រៀបពិធី ១ សម្រាប់តាំងឈ្មោះកូនគាត់ៗ យកក្បួនគេចមកបើកមើលឫក្សពារពេលា ឲ្យកូនគាត់រួចគាត់ទាយទុកថា កូននេះស៊ីខ្សែផ្ចិតទៀតហើយ ព្រោះលេខឆ្លើយថាអត្ថៈ មកជាលាភៈ លាភៈមកជាហីនៈ អានេះកេស៊ីសុំទាន គេចួរជាងធ្វើការឯទៀត តែលាភៈនោះមានអន្តរាយ ដូចជាអញបង់មាស ១០០ តម្លឹងទៅបានឯម៉ែវាមក ទើបគាត់ឲ្យឈ្មោះកូននោះថាអាជូជីង ។

ចាប់តាំងអំពីថ្ងៃដែលអាជូជីងកើតមក នាងអមិត្តតាជាមាតា បេះតែពុំស្រួលក្នុងខ្លួនអស់កំឡាំងល្ហិតល្ហៃ ធ្វើការអ្វីៗ ពុំសូវបាន ជាទំរាំនដល់តាជូជុំ ១ នឹងព្រានៅបម្រើនាងអមិត្តតាពុំបានក៏ចាត់ចែងរៀបចំប្រដាប់ប្រដានឹងចេញដំណើរទៅកាន់នគរជេតុត្តរ ដើម្បីទៅសុំព្រះរាជទាននាងកណ្ហានឹងបាជាលីជាព្រះរាជបុត្រា-បុត្រីនៃព្រះបាទវេស្សន្តរ យកមកឲ្យបម្រើនាងអមិត្តតា នឹងការបើតាជូជីង ។ តាជូជកគាត់រៀបចំរានផ្ទះសំ-ណែងមានស្រូវអង្ករ ត្រីងៀត សាច់ឆ្អើរ អំបិល ប្រហុកទុកឲ្យនាងអមិត្តតាបរិភោគកំណត់ ១ ឆ្នាំទើបប្រើអស់ រួចគាត់ផ្តាំនាងអមិត្តតាថា ប្អូននាងនៅឲ្យសុខសម្រាន្ត កុំដើរទៅលេងទីឋានអ្នកដទៃ កុំបង្ខូលកៀរប្រុសតំឡោះ កុំញ៉េះញ៉ោះនឹងអ្នកព្រៀង តាទៅនេះបើជាមានលាភដូចបំណងនឹងវិលមកវិញជាឆាប់មុនកំណត់ ១ ឆ្នាំ បើជាឥតលាភទេ នឹងស្វែង

រកលាភផ្សេងៗតទៅទៀត ។ តាជូជកគាត់ផ្តាំរូប គាត់បើបបញ្ចាស អង្គុលនាងអមិត្តា រូបគាត់លើកអាជូជីនបីទ្រទ្រៀង ហើយគាត់បំពេថា:

"កូនអើយនាងដេកទៅ ទុកពេលឲ្យឪអង្គុលម៉ែ
ឪថែរទៅយូរថៃ ណាកូនចាំបណ្តាំឪ ។
ដេកយប់កូនកុំយំ ខ្លាចមៀមមុំរាំចាំផ្លូវ
ចាប់យកព្រលឹងទៅ កូនពៅអើយនាងឈឺថ្កាត់" ។

ហើយគាត់ងាកទៅលោមនាងអមិត្តាថា:

អមិត្តាបៅតាអើយ តាលាទៅហើយណាទៅណា
ចូរនៅសុខសាន្តកុំកាយា កុំគិតនឹកតាណាទៅអើយ ។
តាទៅមិនយូរប៉ុន្មានទេ ចូរមើលក្បាលកូនត្រាណាត្រើយ
តែបានទទួលលាភស្រេចហើយ ទៅអើយតាវិលមករួសរាន់ ។

តាជូជកគាត់លោមលាស្រេចហើយ គាត់ក៏ស្ពាយស្បូវខាវគោចកាន់ឈើច្រត់ចេញទៅដល់កុំគីរីវង្កតបានជួបប្រទះនឹងព្រះវេស្សន្តរ គាត់ក៏ចូលទៅសុំយកនាងកណ្ហានិងជាលីបានសម្រេចដូចក្តីប្រាថ្នារបស់គាត់។ តាជូជកក៏នាំយកនាងកណ្ហា ជាលីមកតាមលើនគរជេតុត្តរ ។

គ្រានោះ ព្រះបាទសញ្ជ័យដែលត្រូវជាព្រះអយ្យកោឃើញតាជូជកនាំទៅកណ្ហា ជាលីមកក៏ទ្រង់បោះតុក ដើម្បីលោះដោះសាយកនាងកណ្ហា ជាលីៗ បានក្រាបទូលសម្តេចព្រះអយ្យកោអយ្យិកាថា ព្រះ

របិតាបានកប់យកដំឡៅទុកជាមុនតម្កាក់ ១០០ សែនដំឡឹងមាស ។ ព្រះអង្គទ្រង់ដញ្ញាក់តាជូជកៗ ក៏ក្រាបទូលថាមែន ទ្រង់ឲ្យជញ្ជូនយកមាសពីព្រះឃ្លាំងមកតាំងទុកឲ្យតាជូជកពិនិត្យចំនួន ២០០ សែនដំឡឹង ។ តាជូជកបានឃើញគំនរមាសដ៏ច្រើនពន្លឺភ្លឺច្បាស់ហើយ ក៏មានសេចក្តីត្រេកអរជាអនេកអនន្ត គាត់គិតថាអាត្មាអញនឹងក្លាយទៅជាមហាសេដ្ឋីក្នុងជាន់ហ្នឹងហើយ ។ ព្រះបាទស្រីសញ្ជ័យព្រះអង្គចាត់ឲ្យពួកពិសេសរៀបគោជនាហារដប់ល្បៀងតាជូជកជាការតបស្នង ដែលបាននាំព្រះរាជនត្តាព្រះរាជនត្តាមកដល់ព្រះនគរព្រះអង្គ ។ តាជូជកក៏បរិភោគអាហារដែលព្រះរាជទានលៀងនោះ បណ្តាលឲ្យកើតជាជម្ងឺទល់ឬកពុកសៀតស្លាប់ក្នុងរាត្រីនោះទៅ ព្រះបាទស្រីសញ្ជ័យក៏ទ្រង់ចាត់ការរំលាយសពតាព្រាហ្មណ៍តាមរបៀបរួចទ្រង់ឲ្យប្រកាសរកអ្នកឯណា ដែលជាញាតិនឹងខ្មោចតាជូជក ក៏រកគ្មានម្នាក់សោះ ហេតុដូច្នេះទ្រង់ឲ្យបង្វិលមាសទាំងនោះបង្គាលទៅជាព្រះរាជទ្រព្យ ក្នុងព្រះឃ្លាំងមហាសម្បត្តិរបស់ព្រះអង្គវិញទៅ ។

ឯនាងអមិត្តតា នាងក៏ខំផ្ចិតផ្ចង់តម្រង់ចិត្តគោរពក្នុងរង់ចាំស្វាមី ជាយូរឆ្នាំណាស់ពុំមានឮដំណឹងអ្វីអំពីស្វាមីសោះ ដរាបដល់តាជូជីនអាយុបាន ១៥ ឆ្នាំ ក៏នៅតែពុំបានដំណឹងអ្វី ឯតាជូជីនជាក្មេងចៅស្រីអប្បលក្ខណ៍ ធំឡើងដឹងក្តីកាលណា ក៏ចេះតែប្រព្រឹត្តអនាចារពោលពាក្យផ្សេងៗ ហើយ

កាចព្រះហ៊ីនមិនស្គាល់ខុសត្រូវ  អ្នកស្រុកជិតខាងត្អូញត្អែរធុញទ្រាន់ទ្រព្យសម្បត្តិដែលជូជកខូចឲ្យបន្តិចបន្តួច  ក៏លួចលាក់បញ្ចាំស៊ីផឹកទិនលេងល្បែងអស់លើង ។  នាងអមិត្តតាក៏ព្រួយចិត្តឥតស្រាកស្រាន្ត ញាតិសន្ដានជិតខាងគេក៏ចង់ស្អប់គ្រប់ៗគ្នា  មានវេលាថ្ងៃ១អ្នកស្រុកជិតខាងគេក្តៅក្រហាយណាស់  គេក៏នាំគ្នាលួចដុតផ្ទះនាងអមិត្តតា ៗ ក៏ស្លាប់ទៅក្នុងភ្លើងនោះទៅ  សល់នៅតែអាជូជីង  ដោយវានៅក្មេងមានកំឡាំងច្រើនក៏លោតរួចផុតចេញពីភ្លើង  ។  ថ្ងៃក្រោយមកជូលីងត្រូវជាមាអាជូជីងគឺគាត់ត្រូវជាប្អូនតាជូជកបង្កើត  ក៏រើសយកអាជូជីងទៅទុកឲ្យនៅជាមួយ  ដើម្បីថែទាំរៀនប្រដៅឲ្យបានបទតាមសណ្ដាប់អ្នកស្រុក ។ អាជូជីងនៅមិនសុខដោយមាប្រឹតរៀនហួសពេក  ក៏លាមាទៅនៅវត្តតាក្រ  មាក៏នាំយកវាទៅផ្ញើឲ្យនៅវត្តតាមបំណង ។ អាជូជីងវាបានទៅនៅវត្តវេលាណា  វានាំកូនសិស្សក្នុងវត្តនោះខូចអស់  ពេលក្រោយវានាំពួកសិស្សវត្តចេញទៅលួចបេះអំពៅទន់លួចមាន់ទាអ្នកស្រុកយកទៅលក់ឲ្យចិនដើម្បីយកប្រាក់ទៅដាក់កំណល់គ្រូស្នេហ៍  អាជូជីងចូលចិត្តផ្គាប់គ្រូស្នេហ៍ដើម្បីរៀនស្នេហ៍យកទៅដាក់ស្រីៗ  ។  គ្រូស្នេហ៍បានតំណល់ច្រើនក៏បង្រៀនស្នេហ៍ឲ្យអាជូជីង ១ មេ  គឺស្នេហ៍ករវិកថា ‹ ឧម: ខ្ញុំនហួតហែតខ្ញុំនថែតស្នេហា  ឃើញអញសន្ធប់ឡើនឡង់  មៈមៈឯហាឯហា ›› ។ គ្រូប្រាប់ថា  បើស្រឡាញ់ស្រីណាឲ្យយកដុំដីមកសូត្រ ៧ ចប់  ផ្លុំដុំដីហើយ

បោលដម្រង់ខ្លួនស្រីនោះៗ ទឹងដេញអ្នកឯងរហូតដល់ផ្ទះ ។ អាជូជឹង រៀនបានមេស្នេហ៍ហើយ ក៏ដើរចូលទៅមើលស្រីៗ ដែលគេកំពុងតូន កំខ្សាច់នៅវត្តតាក្រែ លុះសំគាល់ឃើញស្រីម្នាក់ជាទីពេញចិត្តហើយ ក៏ចាប់ផ្ដុំដៃយកមកសូត្រគាថានោះបាន ៧ ចប់ ក៏បោលដម្រង់ទៅត្រូវ ក្បាលស្រីនោះៗ ទឹងក៏នាំបងប្អូនដេញ អាជូជឹងក៏រត់ដម្រង់ទៅផ្ទះ ស្រីៗ មានក្រុងទានបាស់ ក៏បះតែដេញតាមអាជូជឹងៗរត់បណ្ដើរគិតបណ្ដើរថា ស្នេហ៍អញពូកែណាស់ អញដាក់តែ ១ ត្រូវស្រី ១ ហ្វូងៗ លុះដេញទាន់ គេក៏យកគេណាក់ទាត់ហើយគេជេរជៀលពូជប្រជួបសន្ធាន គេចាប់បង់នាំ យកទៅប្រគេនលោកគ្រូវត្តតាក្រែៗ លោកខ្ញាល់បង្គាប់ឲ្យបងហាលថ្ងៃ ពល់ល្ងាច ។ អាជូជឹងបេះតែនឹកឆ្ងល់ថា អញបានរៀនស្នេហ៍ឥស្ ប្រាក់គរគោឥអញបានប្រថុះតែគ្រោះកាចយ៉ាងនេះ អញនឹងទុកស្នេហ៍ នេះតទៅទៀតពុំបានទេ គិតហើយក៏យកស្នេហ៍នោះទៅប្រគល់ឲ្យគ្រូ វិញ ។ គ្រូសួរថា កាលឯងបោលគេនោះ តើព្រត្រូវត្រង់ណា អាជូជឹងថា ត្រូវត្រង់ក្បាល គ្រូស្នេហ៍ថា ចុះឯងខុសហើយអញបង្គាប់ ឲ្យបោលខ្លួន ឯងទៅបោលក្បាលបានជាពរ៉ែឲ្យយ៉ាងហ្នឹង ល្មើយឯង លែងរៀនទៅ តែម្ដងទៀត ឯងមុខតែជាប់គុកមិនខានឡើយ ។

ក្រោយជូលឹងជាប្អូនតាជូផុបានព្រងណ៏ងថា តាជូផកគាត់ទទួល អនិច្ចកម្មនៅក្រុងដេតុកានតាទៅហើយ គាត់មានមតក ២០០ សែន

គម្ពីរមាសខុននៅក្នុងព្រះឃ្លាំង ដូលីនគាត់គិតថា ដូចគាត់មានកូនប្រុសឈ្មោះអាដូដាំង ឥឡូវអាយុទើបបាន ១៩ ឆ្នាំ អាក្មេងគួរនាំចូលទៅទទួលមរតកទាំងនោះ ព្រោះថាជាអ្នកសុំមតិកមានដាំឡៃ ដូលីនគិតដូច្នោះហើយក៏ចាត់ចែងស្បៀងអាហារនិងសោហ៊ុយផ្សេងៗ បានស្រេច ហើយគាត់ក៏នាំអាដូដាំងចេញពីនគរកលិង្គរដ្ឋម្រង់ទៅនគរជេតុត្តរអស់ ២ ខែ ២០ ថ្ងៃទើបបានដល់ ដូលីនគាត់នាំអាដូដាំងចូលទៅជួបនឹងចាងហ្វាងព្រះឃ្លាំងមហាសម្បត្តិ តបថា ពិតមែន តែបើអ្នកចង់បានមតិកនេះត្រូវតែអ្នកជូនភស្តុតាង គឺសំបុត្រអត្រានុកូលដ្ឋានផ្សេងៗ ដូចតទៅនេះ :

១ ) សំបុត្ររៀបការរបស់បាដូដាងនិងរបស់នាងអមិត្តាដែលបានរៀបការយកគ្នាជាប្តីប្រពន្ធតាមច្បាប់ -

២ ) សំបុត្រកំណើតរបស់បាដូដាងនិងសំបុត្រកំណើតនាងអមិត្តា-

៣ ) សំបុត្រមរណភាពរបស់បាដូដាងនិងសំបុត្រមរណភាពរបស់នាងអមិត្តា -

៤ ) សំបុត្រកំណើតអាដូដាំង -

៥ ) សេចក្តីចក់ហេតុ ពីវង្សត្រកូលបាដូដាងនិងនាងអមិត្តានិងសេចក្តីបញ្ជាក់ពីវង្សត្រកូលនេះ ត្រូវស្តេចនគរកលិង្គរដ្ឋទទួលស្គាល់ផង ។

លិខិតទាំងឡាយដូចរៀបរាប់ខាងលើនេះ ត្រូវបិទតែមកុង ១ សន្លឹក ១រ,២០ ហើយមានសេចក្ដីបញ្ជាក់ពីព្រះមហាក្សត្រនគរគលិន្ទរដ្ឋផងទើបប្រើការបាន ។

លិខិតទាំងឡាយនេះ ត្រូវអ្នកនាំយកមកជូនតុលាការខាងនគរជេតុត្តរ ព្រមជាមួយនឹងពាក្យ ១ ច្បាប់ដែលសុំទទួលយកមតិកនៃអោចកាជូដក ។ រឿងនេះត្រូវអ្នកគិតគូរឲ្យបានឆាប់ឲ្យទាន់ពេលវេលា ព្រោះមតិកនេះមានអាយុតែត្រឹម ៩ ខែទៀតទេ ទីងផុតកំណត់ ៥ ឆ្នាំហើយ ទំនងទាមទារតទៅអ្វីទៀតពុំបាន ។ លោកតាងហ្វាន់ព្រះយ៉ាំងមហាសម្បត្តិ អធិប្បាយប្រាយប្រាប់រៀបច្បាប់ឲ្យជូលីងស្ដាប់ដូចខាងលើនេះ ជាការស្រេចតាមច្បាប់សម្រាប់នគរជេតុត្តរមែនៗ ។

ឯជូលីងកាលបានស្ដាប់សព្វគ្រប់ទៅគាត់គិតឃើញថា រឿងមតិកនេះជាការតឹងតែងពន់ពេកណាស់ ព្រោះលិខិតទាំងប៉ុន្មានដែលលោកព្រះយ៉ាំងមហាសម្បត្តិប្រាប់ពន្យល់ឲ្យធ្វើនោះ នៅនគរគលិន្ទរដ្ឋ ឥតមានធ្វើទេ គ្មានអ្នកឯណាដែលស្គាល់ជីងព្វសោះ ទើបគាត់ងាកទៅនិយាយនឹងអាជូជីងថា ណ្ហើយអាជូជីងយើងគួរត្រឡប់ទៅស្រុកយើងវិញចុះ មើលទៅគ្មានបន្សំអ្វីដល់គិតគូរសោះឡើយ ទើបអាជូជីងតបថា អើបើយកមតិកមិនបានក៏ហើយទៅចុះ តែលោកមាគិតទារយកតែជាតុផ្ទុកខ្ញុំឲ្យបាននាំយកទៅស្រុកវិញចុះ ។ ជូលីងព្វជូហោះក៏នឹកឃើញថា មែនហើយៗ

ចូលទៅជួបនឹងលោកព្រះឃ្លាំងម្តងទៀត ដើម្បីសួររកធាតុនៃខ្មោច តាជូជក ។ លោកព្រះឃ្លាំងតបថា ចំនៀមស្រុកនេះ គេមិនដែលទុកធាតុខ្មោចមនុស្សឯណាថា ឥតញាតិសន្តានទេ គឺគេតែងយកទៅដុតចោលជាផេះ ចូរអ្នកកុំរំពឹងនឹងរកធាតុនោះឡើយ ។ ជូលីននឹងតាជូជីនមើលមុខគ្នាទៅវិញទៅមក ហើយក៏លាលោកព្រះឃ្លាំងចេញមកខាងក្រៅ ក៏នាំគ្នាបេះតែដើរដ្រកដ្រៀតតាមផ្លូវតូចផ្លូវធំ ស្រាប់តែទៅជួបនឹងស្មាក្តីម្នាក់កំពុងស៊ីផឹកនៅផ្លូវ ។ ឯស្មាក្តីបានឃើញមនុស្សចំឡែកបណ្តើរគ្នាតាមផ្លូវ ក៏ហៅទៅសាកសួរដឹងរឿងសព្វគ្រប់ហើយ ស្មាក្តីនោះក៏និយាយរ៉ាប់រងថា ខ្ញុំយកមកនោះឲ្យបាន ធានានឹងកេលខិតទាំងប៉ុន្មាន ដែលលោកព្រះឃ្លាំងបង្អាប់នោះឲ្យបានផង តែអ្នកខឹងឲ្យយើងប៉ុន្មាន ។ ជូលីនតបថា ខ្ញុំមានអំណរណាស់ តែថាខ្ញុំជាអ្នកដំណើរមកពីឆ្ងាយ មានប្រាក់កាសបន្តិចបន្តួចសម្រាប់ធ្វើជាសោហ៊ុយវិលទៅស្រុកវិញ ។ ស្មាក្តីថា បើមិនទាន់បានមកគិតមិនទាន់យករង្វាន់គ្នាទេ ជូលីនក៏ជូរទ្រូងបន្តិច ហើយស្មាក្តីនិយាយថា ណ្ហើយការនេះយើងឈប់និយាយសិន ដ្បិតដល់ពេលបរិភោគអាហារហើយ ចាំក្រោយសឹមជួបនិយាយគ្នាម្តងទៀត ប៉ុន្តែអ្នកត្រូវលៀងយើង ១ ពេលសិន ព្រោះយើងជួយពិគ្រោះរឿងរបស់អ្នកអស់ ១ ព្រឹកទៅហើយ ។ ជូលីនគិតថា ស្មាក្តីនោះបេះនិយាយប្រាប្រះគ្រាន់បើ គួរទទួលលៀង

ប៉ាយ ១ ពេលទៅចុះ ដើម្បីទុកនិយាយតាតទៅទៀត គិតដូច្នោះ ហើយក៏នាំសាក្សីទៅផ្ទះលក់បាយ បង្គាប់ឲ្យពួកពិសេសរៀបអាហារឲ្យ សាក្សីបរិភោគរួមជាមួយនឹងខ្លួន រួចស្រេចគិតសោហ៊ុយអស់ ២០ រូបិយ ហើយសាក្សីប្រាប់ថា អ្នកថយទៅស្រុកសិនចុះរកសោហ៊ុយខ្លះ យកមកវិញលុះចិតៈផ្សេងៗចូលតក់យកមកតិក ។ ជួលនឹកនាំអាជ្ញដឹងត្រឡប់ទៅស្រុកវិញ លុះនាំគ្នាដើរកាត់ព្រៃភ្នំក្រៃថ្ងៃទៅ ស្រាប់តែប្រទះនឹងមេខ្លាបណ្ដើរកូន ខ្លានោះក៏ចាំផងទាំងពីរនាក់ស្ទាប់យកទៅបរិភោគអស់ទៅ ។

ចប់រឿងអាជ្ញដឹងតែប៉ុណ្ណោះ ។

សំ - ស៊ុន

# ព្រះគ្រូបញ្ញាលិខិត កៅ-សឹម

គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

(តមក)

---

ឯយើងទាំងពីរនាក់មិនដែលលះបង់ពាក្យពោលគ្នាឡើយ បើព្រះអង្គបញ្ជូនភរិយាខ្ញុំទៅកាន់ព្រៃហិមពាន្តមុនហើយ សូមទ្រង់សម្លាប់ទូលបង្គំជាមុនសិន ហើយសឹមបញ្ជូនភរិយាខ្ញុំទៅជាខាងក្រោយ ៗ ព្រះរាជាទ្រង់ត្រេកអរឲ្យកិន្នរទាំង ២ ទំលើសុវណ្ណបញ្ជរហើយត្រាស់ឲ្យហៅព្រានព្រៃមកឲ្យយកទៅលែងឯព្រៃហិមពាន្តទាំង ២ទៅ កិន្នរទាំង២ រូបដែលបានរួចខ្លួនមិនស្លាប់ ព្រោះមិនពោលពាក្យទុព្ភាសិត ៗ

ចប់រឿងសេចក្តីស្អាត ៣ យ៉ាងនឹងច្បាប់ស្មៀន ៣ យ៉ាង

---

## ភត្តសោណ្ឌា[១]

សេចក្តីថា: ពួកសត្វនិករដែលកើតមកក្នុងសកលលោកទាំងមូលសុទ្ធតែជាសត្វបរិភោគអាហារចំណី គ្មានអ្នកណាមួយវៀសវាងបានឡើយ សូម្បីតែទេវបុត្ត-ទេពតា ក៏បរិភោគចំណីអាហារទិព្វដែរ តែជាចំណីអាហារទាំងនោះ ជាវត្ថុមានរសជាតិ មានទ្រង់ទ្រាយនិងពណ៌សម្បុរ

---

១ ជនអ្នកលេងស៊ីភត្តទាំងឡាយ ៗ

ប្លែកៗអំពីគ្នា, ខ្លះមានរសជាតិឆ្ងាញ់ពិសា ខ្លះមានរសជូរ-ចត់-ល្វីង-ហឹរ ផ្អែមជាដើម ខ្លះមានពណ៌ស-ក្រហម-លឿងជាដើម ខ្លះចំអិននឹងភ្លើង ខ្លះមិនចំអិននឹងភ្លើង សុទ្ធសឹងតែចម្រុះលាយដោយវត្ថុផ្សេងៗ ទើបកើតឡើងជាចំណីអាហារ ។ គឺចំណីអាហារទាំងនេះ មានដម្លៃខុសៗអំពីគ្នា ខ្លះមានថ្លៃច្រើន ខ្លះមានថ្លៃតិច តាមបែបផែនដែលគេផ្សំគ្រឿងធ្វើ និងតាមបែបប្រទេសស្រុកដែលប៉ុនប្រសប់ធ្វើនិងមិនប៉ុនប្រសប់ធ្វើប៉ុណ្ណោះ ជារបស់មានរសជាតិប្លែកៗគ្នាជាដរាប ។

ចំណីអាហារជាគុណសម្បត្តិឲ្យអ្នកបរិភោគ ចំរើនសរីរៈឲ្យធាត់ធំល្អ ឲ្យមានកំឡាំងរឹងប៉ឹងល្អ ឲ្យមានស្មារតីដឹងលំនឹងខ្លួន និងឲ្យមានធាតុទាំង ៤ ប្រព្រឹត្តទៅស្មើគ្នាស្រួល ព្រមទាំងឲ្យមានឆវិវណ្ណសម្បុរស្បែកល្អផង ។

ឯចំណីអាហារដ៏ខ្ពង់ខ្ពស់ មានរសជាតិឆ្ងាញ់ក្រៃលែងជាងចំណីអាហារនានានោះ ត្រូវដឹងថាជាអាហារតែងនឹងនាំមនុស្សដែលធ្លាប់បរិភោគឲ្យញ៉ាំមិនភ្លេចគេចមិនផុត ចូលទៅរកទីដំណែងនៃហាងលក់រឿយៗ ឲ្យជាប់ចិត្តគាន់គំនិតភ្លេចនឹកនាដល់សេចក្តីទាល់ក្រ និងសេចក្តីអន្តរាយផ្សេងៗ ហាក់ដូចជាចាប់មនុស្សគ្រងស្រេចទេសៈទៅលក់ដូរផងដែរ ព្រោះថាចំណីអាហាររមែងទាញចូលស្រូបមនុស្សឲ្យលុះជាប់ដោយរសជាតិរបស់វា ។

មនុស្សណាចូលចិត្តតែនឹងចរណ៍អាហារបែបនេះ វេលាដល់អាហារវិបត្តិប្រែប្រួលសូន្យទៅតាមកាលៈទេសៈហើយ មុខជាត្រឡប់ទទួលរងគ្រោះថ្នាក់ ធ្លាក់ដល់សេចក្ដីទុក្ខយ៉ាងធំជាងមនុស្សធម្មតាបរិភោគអាហារតាមធម្មតាតាមមានតាមបាន ។

ហាក់ទីងថា ដូចជាអ្នកស្រុកប្រណែនមិនចង់ឲ្យគេទទួលទានភោជ-នាហារដ៏ថ្លៃថ្លា ប្ដូរយកកំណាញ់មិនឲ្យគេចាយលុយកាក់ប្រាក់កាសរបស់គេ ពិតជាដូច្នោះខុះមែន ! ក៏សូមអស់លោក-អ្នកទៀងកាន់ទីដំណែងក្នុងនោះ ត្រូវពិគ្រោះដល់ធនធានទីផ្ទះសម្បែងរបស់ខ្លួនឲ្យជាក់ច្បាស់ ហើយសឹមបរិភោគឲ្យពល់ពេលទៅចុះ ។ តែថាត្រូវរឹករំពឹងដល់បច្ច័យ ២ យ៉ាង:

១ - អន្តោបច្ច័យ បច្ច័យដែលត្រូវតាក់តែងខាងក្នុងផ្ទះ

២ - ពាហិរប្បច្ច័យ បច្ច័យដែលត្រូវតាក់តែងខាងក្រៅផ្ទះ ។

ឯអន្តោបច្ច័យ បច្ច័យដែលត្រូវតាក់តែងខាងក្នុងផ្ទះនោះ ត្រូវរឹករំពឹងថា: សព្វថ្ងៃនេះអាត្មាអញមានគ្រឿងអាភរណៈ ស្លៀកពាក់គប់គ្រាន់ដល់ប្រពន្ធកូនទីងក្រុមញាតិហើយឬ? មានគ្រឿងស្បៀងអាហារចិញ្ចឹមជីវិតល្មមគប់គ្រាន់ហើយឬ? មានទីលំនៅផ្ទះសំបែងក្នុងដេតគ្រួសារ ទីងគ្រឿងប្រដាប់សំរាប់ប្រើប្រាស់តែងតាំងនៅក្នុងផ្ទះគប់គ្រាន់ហើយឬ? មានគ្រឿងកេសជ្ជថ្នាំកែរោគគប់គ្រាន់បរិបូណ៌ហើយឬ? បើ

បច្ច័យខាងក្នុងមានបរិបូណ៌ហើយ តែខ្វះអាហារប្បច្ច័យ បច្ច័យខាងក្រៅនោះក៏ប្រព្រឹត្តទៅមិនរួចដែរ តោងតែឲ្យមានអាហារប្បច្ច័យផង ទើបប្រព្រឹត្តទៅរួច ។

ឯអាហារប្បច្ច័យនោះ ត្រូវនឹងពាក្យថា សព្វថ្ងៃនេះគាត់អញមានយានពាហនៈ ទីងនាក់តូចធំសំរាប់ជិះបរលេងខាងលើគោក លើទឹកគ្រប់គ្រាន់ដល់ខ្លួននឹងគ្រួសារហើយឬ? កាលបើបច្ច័យខាងពីរនេះមានបរិបូណ៌ហើយ ទោះបីនឹងដើរចេញទៅឬចាយប្រាក់កាសទិញបណ្ដាអាហារបរិភោគនោះទើបបៀសវាងនូវសេចក្ដីអន្តរាយបានខ្លះ ។

មនុស្សខ្លះគិតតែងតែខាងក្រៅ ឯខាងក្នុងមិនបានតែង គឺថា: ទីលំនៅៗ ផ្ទះពោនសំណាក់អាស្រ័យគ្មាន ស្បៀងអាហារគ្រឿងចិញ្ចឹមជីវិតឲ្យល្មមគ្រប់គ្រាន់ដល់ប្រពន្ធកូនក្រុមញាតិ ដែលប្រៀតនៅរួមសុខទុក្ខជាមួយក៏គ្មាន គ្រឿងប្រដាប់សំរាប់ប្រើប្រាស់ក្នុងផ្ទះក៏គ្មាន ហើយប្រឹងតែងតែខាងក្រៅ គឺចាយលុយកាក់ស្លៀកពាក់យ៉ាងល្អ បរិភោគបណ្ដាអាហារលេចបួលទៅរួច ។

មនុស្សយើងត្រូវយោលគំនិតគិតបែងកាលជា ២ ចំណែក:

១ - កាលរឹងកុំបែងឲ្យឈឺ

២ - កាលឈឺបែងឲ្យរឹង ។

ឯកាលរៀនកុំបែងឲ្យខ្ចីនោះ ត្រូវដឹងថា: មនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ សុទ្ធសឹងតែមានមាតាបិតាភរិយាបុត្រ ក្រុមញាតិពូជពង្សបញ្ជាប់ចម្ងាប់សំរាប់រក្សាជាតិគ្រប់ៗគ្នា ក៏ក្នុងត្រកូលនិមួយៗនោះមានចរិយានិងការប្រព្រឹត្តត្រឹមត្រូវក៏មាន មិនប្រព្រឹត្តត្រឹមត្រូវក៏មាន ការស្លៀកពាក់និងគ្រឿងប្រើប្រាស់សុបុកលើសខ្វះជាងគ្នាខ្លះក៏មាន ដូចគ្នាខ្លះក៏មាន ស្មើគ្នាខ្លះក៏មាន ព្រមទាំងឋានៈយសទ្រព្យសម្បត្តិលើសខ្លះដូចគ្នាខ្លះ ស្មើគ្នាខ្លះក៏មាន មិនសូវដូចគ្នាទាំងអស់ឡើយ ។ តែថាដែលដូចគ្នានោះ គឺមាតាបិតា ភរិយាបុត្រ និងគ្រឿងឈ្មោះរបស់ខ្លួននេះហើយ ជាគ្រឿងតាំងគោលដើមរបស់មនុស្សដែលរស់នៅក្នុងលោកនេះ ។ មនុស្សត្រូវតែគិតដល់សេចក្ដីស្រេកឃ្លាន ការខ្វះខាតរបស់ជនទាំងនោះ ត្រូវជួយបីបាច់ចិញ្ចឹមថែរក្សាការពារ កុំឲ្យមានសត្រូវណាមួយមកបៀតបៀនបាន ព្រោះជនទាំងនេះហើយជាអ្នកតំណាងជាតិទឹកដី ប្រដៅកូនចៅប្រុសស្រីមិនឲ្យប្រព្រឹត្តធ្វើអំពើហួសខាង យសស័ក្តិ ពូជពង្សបញ្ជាប់ចម្ងាប់ និងទំនៀមរបស់ស្រុកដែលសម្រាប់ទុកឲ្យជាគ្រឿងកាលរៀនដល់កូនប្រុសស្រី មិនគួរកូនប្រុសស្រីបែងការនេះឲ្យខ្ចីទៅវិញឡើយ ត្រូវប្រមាណឲ្យសមគួរដល់ជាតិត្រកូលរបស់ខ្លួនប៉ុណ្ណោះឯង (កុំស្ទុះឲ្យហួសផុតបន្ទាល់ឡើយ) តែមានមនុស្សខ្លះមានគំនិតគិតយករស់តែម្នាក់

ឯង ឥតមានគិតដល់មាតាបិតាក្រុមញាតិរបស់ខ្លួនឡើយ ឈ្មោះថាជាមនុស្ស (វែកប្រឡោះឲ្យចុះតែខ្លួន ១) ។

ឯណាលទ្ធិបែងឲ្យវែងនោះ ត្រូវដឹងថា: មនុស្សយើងកើតមកមានអាយុខ្លី របរកស៊ីចុកកខ្វះ ទីលំនៅនឹងគ្រឿងប្រើប្រាស់ក៏ខ្វះ បុណ្យស័ក្តិទីទៃគេរ ឈ្មោះក៏ខ្លី មិនតាំងនៅយូរប៉ុន្មានឡើយ គង់នឹងវិនាសបាត់ មិនត្រូវធ្វើសេចក្តីបង្ហៀរអោយាជ ព្យាបាទគំនុំគេរឿងបៀតបៀនគ្នាទៅវិញទៅមកឲ្យតែលដល់តែដល់សេចក្តីវិនាសអន្តរាយទ្រព្យសម្បត្តិ ខ្លួនគេក្តីឈ្មោះយសស័ក្តិធ្លាក់ទៅជាមនុស្សថោកទាបដល់ត្រកូលជាតិស្រុកទេសវៀងខ្លួនគេសេចក្តីសុខនោះគ្មានឡើយ ត្រូវធ្វើអ្វីមួយទុកជាប្រយោជន៍ដល់ជនដែលកើតមកខាងក្រោយ កុំឲ្យបាត់ឈ្មោះខ្លួនឲ្យបានកាលគវែងទៅ ។

សូមបំភ្លឺសេចក្តីជាពាក្យកាព្យយ៉ាងខ្លីដូចតទៅនេះ

## កាព្យពាក្យ ៧

លោក- អ្នកបរិភោគអាហារថ្លៃ ចាយលុយលោសព្វថ្ងៃមិនទំនា
ដល់កូនប្រពន្ធនៅរំពា គ្មានភោជនាយ៉ាងដម្លៃ ។
ឡើងលើកៅអីបង់ចំនែន លើកជើងគងជែងសង្កត់ដៃ
ស្រូបតុទឹកមុខសប្បាយក្រៃ ក្អួចមើលរំពាក្អូក្អូច ។

ដែលចិនវាកត់ឈ្មោះនៅផ្លាក[១] កុំឲ្យពិបាកការឡូវឡា
តាំងហៅអាចិនមកប្រាប់ថា ឲ្យធ្វើភក្សា[២] តាមត្រូវចិត្ត ។

ចិនលើកអាហារដាក់លើតុ ដបស្រាចំមុខបើកឆ្នុកបិទ ចាប់កែវចាក់ស្រាដាក់មកជិត ស្ងួយលើកផឹកតក់ៗផឹក ១ ផ្អឹក ៗ ចាប់សមស្លាបព្រាបូកប៉ាយម្ហូប អណ្តាតតាវស្រូបលេបបួបត្រឹក ឆាម៉ីសាច់សាតផតមានទឹក ស្លាបព្រាសមញឹកចាក់ភ្លាត់ខ្លួន ។ ឆ្អែតស្រេចយកឈើមកចាក់ធ្មេញ ស្អាតលើងធ្មេញអស់ផ្អឹងផ្អែន ជូតដៃជូតមាត់ខិងកន្សែង ដក់ប៉ារីផ្សែងបន្ទុយព្រាត ។ ក្រោកឡើងដើរគន់ត្រឡប់កាយ ដើរលេងសប្បាយដល់អន្ធការ ទើបមកដល់ផ្ទះផ្តែព្រសព្រាត ប្រពន្ធដៀលមារយាទបាត់ត្រកអរ ។ កើតឈ្មោះប្រកែកជជែកគ្នា ទំព្រាមតិកជិបវរ ទំហូពេជ្រមាសពុកក៏ជរ ជាគ្រូគោតវតិមាតា ។ លបលួចទៅលក់ប្តូបញ្ចាំ កខ្ទង់ថ្ងៃខែឆ្នាំឆ្លុតបេ្តជ្ញា បំផ្លាញគ្មានសល់របស់ណា យកដីត្រឹមហាបញ្ចាំទៀត ។ បញ្ចាំចាំនស្រែចំការបេច សូន្យឈ្មោះសូន្យលេខផុតអស់ស្មៀត មិនដឹងគិតកែលក់អ្វីទៀត ដើរតៀតគៀតបៀតសុំគេស៊ី ។ វេហអស់លោក-អ្នកតាំងប្រុសស្រី កុំធ្វើមេត្រអ្នកញ៉ាំញី លក់ទ្រព្យសម្បត្តិអស់ខ្ទេចខ្ទី ដល់ទីខ្លួនជោកអស់ជន់ប្រាក់ ។ (មានត)

---

១ ភាសាបារាំងសែស (plaque) (ក្តារសម្រាប់សរសេរអក្សរកត់ឈ្មោះម្ហូប) ។
២ ភត្តាហារគ្រប់យ៉ាងដែលបុគ្គលបរិភោគ ។

## សុភាសិត និង ការគោរព

# លោកមហា "សៅរ៍ - លីវ"

វត្តសោយ ឃុំមៀន ស្រុកកោះសូទិន ខេត្តកំពង់ចាម

(តមក)

---

សជីវិតំ បរិច្ចជេ វិញ្ញូ ភាគោ សទេសតំ
គេហំ ធារំ ការំ ឧភេ ធារុអយំ បរិច្ចជេ ។

បង់ឲ្យប្រទេសខ្លួនវិញ្ញូនា ត្រូវបរិច្ចាគលះជីវិត បង់ធ្វើត្រឹមហានាក់ឲ្យជិត តាំងចិត្តលះឈើទីងដែកកុំស្តាយ ។

សច្ចំ វេ អមតា វាចា ឯាឌគោត្តំ ឱ ជីវតំ
អប្បមត្តា ឆ មិយន្តិ និព្វានំ អជរាមតំ ។

វាចាសត្យជាពាក្យមិនស្លាប់ពិត នាមគោត្រកិត្តិឥតស្លាប់សោះសា ជនមិនប្រមាទមិនមរណា និព្វានឋានសុខាមិនចាស់ស្លាប់ ។

សុភាសិតថា

ស្លាប់រូបកាយកុំឲ្យតែស្លាប់កេរ្តិ៍ ស្លាប់ពលរេហ៍កុំឲ្យតែស្លាប់នាយ ស្លូវស្លាប់ប៉ាកុំឲ្យតែស្លាប់ម្តាយ នេះពាក្យបរិយាយបុរាណ ។ យប់ងងឹតកុំឲ្យតែខ្វាក់ខែត្រ ផល់ចក្ខុភេទកុំឲ្យតែខ្វាក់ចិត្ត ស្លូវបង់ទ្រព្យកុំតែបង់កាយា ស្លូវបង់គាត្ថាកុំតែបង់វដ្ត ។

ឧដ្ឋានវតោ សតីមតោ

សុចិកម្មស្ស និសម្មការិនោ

សញ្ញតស្ស ច ធម្មជីវិនោ

អប្បមត្តស្ស យសោភិវឌ្ឍតិ ។

ជនដែលព្យាយាមប្រឹងប្រែងឃ្មាតខ្មី មានស្មារតីដឹងជាធម្មតា ចេះចាត់ការស្អាតចាកទោសា គួរដោយប្រាជ្ញមុនដែលគិតធ្វើ ។ សង្រួមទប់កាយវាចានូវចិត្ត ចិញ្ចឹមជីវិតតាមធម៌ស្មើ ៗ មិនប្រមាទធ្វេស ក្នុងកិច្ចសិតេ រមែងចំរើនទ្រេះទ្រើសដោយយសា ។

ភមរានំ រតី បុប្ផេ បក្ខីនំ នភាលយេ

មុនីនំ រតិ សទ្ធម្មេ មហេសីនំ តបោវនេ ។

ភមរជាតិត្រេកនឹងបុប្ផា បក្សីបក្សាត្រេកនភាល័យ ប្រាជ្ញមុនីត្រេកធម្មវិន័យ មហាឫសីត្រេកតបោវ័ន ។

ឧដ្ឋានកាលម្ហិ អនុដ្ឋហានោ

យុវា ពលី អាលសិយំ ឧបេតោ

សំសន្នសង្កប្បមនោ កុសីតោ

បញ្ញាយ មគ្គំ អលសោ ន វិន្ទតិ ។

ជនយុវ័នដែលមានកាយពល មិនប្រឹងខ្វាយខ្វល់ក្នុងកាលត្រូវប្រឹង ប្រកបដោយក្តីខ្ជិលច្រអូសរំង ស៊ុំដេករំពឹងចាំវាសនាវិញ ។ លិចលង់ចប់ក្នុងភក់គឺបាបសង្ខ មានចិត្តមិច្ឆាវិតក្កជ្រក់ជ្រេញ យុវ័នមហា·កំដិលនោះពេញ ទ៏មិនបានមិញគារ្យមគ្គដោយញាណ ។

មិទ្ធី យទា ហោតិ មហគ្ឃសោ ច

និទ្ទាយិតា សម្បរិវត្តសាយី

មហាវរាហោវ និវាបបុដ្ឋោ

បុនប្បុនំ គព្ភមុបេតិ មន្ទោ ។

ជនណាមានក្តីជនមិទ្ធី បានតែល្មោភស៊ីច្រើនជ្រុលមាត្រា និទ្រានទៀលត្អក់លង់កាលា ដូចមហាសូក្រាជ្រូកស្រុកអប្រិយ ។ ដែលគេបំប៉នបំការន់សញ្ញា ដោយទឹកបាកណ្តុំចំណី នរជននោះពិតពេញពាលមុឡ្ហី តែងសម្ព័ក្នុងគភ៌រឿយៗ ។

មនុជស្ស សទា សតីមតោ

មត្តំ ជានតោ លទ្ធភោជនេ

តនុកស្ស ភវន្តិ វេទនា

សណិកំ ជីរតិ អាយុ បាលយំ ។

ជនអ្នកមានស្មារតីជម្មតា ដឹងមាត្រាក្នុងលទ្ធភោជន តែងមានទុក្ខវេទនាតិចទន់ ទាំងជន្មត្រូវព្យាបាលក៏ជកស្បែក ។

ទិសោ ទិសំ យន្តំ កយិរា វេរី វា បន វេរិនំ

មិច្ឆាបណិហិតំ ចិត្តំ បាបិយោ នំ តតោ ករេ ។

ធម្មតាចោរឃើញចោរ ឬចោរ ជនមានពៀរយល់ជនពៀរ បិនព្យសន៍ព្យាបាទនូវគ្នានឹងគ្នា កើតទោសវេទនាគួរបំភ័យ ។ តែឯចិត្តដែលគេដាក់ខុស មានកំហុសលាមកលើសនោះក្រៃ ធ្វើគេឲ្យនឹងទុក្ខអសង្ខៃយ្យ ដ្បិតនិស្ស័យចិត្តបាបអបាយទាញ ។

សប្បាយកុំសប្បាយមិនសប្បាយ សប្បាយកុំសប្បាយពាល់តែភ្លាត់ សប្បាយកុំបែបសត្វគេគន្ធាត់ សប្បាយក្នុងវដ្តប្រាជ្ញត្រិះរិះគន់ សប្បាយកើតមកពីមានសម្បត្តិ សប្បាយខ្លាតបាត់មកពីសូន្យធន សម្បត្តិមានមកពីសិល្បសាស្ត្រមន្ត ក្រគ្រន់ព្រោះមន្តធនសូន្យផង បាបធ្ងន់បុណ្យទន់ភិតទង្គិចទុក្ខ បាបបុកសុខបោលបាក់ធ្លាក់ទុក្ខគ្រែង បុណ្យមានបានសុខមិនសោកវង្វេង សូន្យបុណ្យព្រេងសុខប្រាសក្រឡាស់ខាន ។

បុណ្យមានបាបមានសុខមានទុក្ខមាន មានផលតាមស្ថានមានធម្មតា តែមើលមិនឃើញគ្រប់តែប្រាជ្ញ ត្រូវតាំងចិត្តបង្ការជានិច្ច ។

ទុល្លភោ បុរិសាជញ្ញោ ន សោ សព្វត្ថ ជាយតិ

យត្ថ សោ ជាយតិ ធីរោ តំ កុលំ សុខមេធតិ ។

• បុរសអាជានេយ្យប្រាជ្ញចំណាន  ក្រនេបានពុំកើតសព្វស្ថានក៏
បើកើតនៅក្នុងត្រកូលឯណា  ត្រកូលនោះបានដល់មហាសុខ ។

នក្ខត្តំ បដិមានេន្តំ  អត្ថោ ពាលំ ឧបច្ចគា
អត្ថោ អត្ថស្ស នក្ខត្តំ កឹ ករិស្សន្តិ តារកា ។

ពួកពាលខ្លៅនៅតែជឿថានក្សត្រ  តែងលាញទ្រព្យសម្បត្តិ
ប្រយោជន៍អធិក  ប្រយោជន៍ដែលបានជានក្ខត្តឫក្ស  ដេកនឹករំពឹងតាម
បានការអ្វី ។

ខ- ពាលខ្លៅនៅតែជឿថាតារា  ផ្សងតាមវាសនាពឹង
បុណ្យផ្កាយព្រឹក  មិនខំខ្វល់ខ្វាយឲ្យពេញសន្ទឹក  សំកុកមមឹកពឹងផ្កាយ
លើមេឃ  ទ្រព្យធនប្រយោជន៍លោកទាំងប៉ុន្មាន  ដែលខ្លួនគេបាន
ដោយប្រឹងពន់ពេក  លោកចាត់ជានក្ខត្តឫក្សឯក  ពីផ្កាយលើមេឃ
ផ្កាយធ្វើអ្វីឲ្យ ។

សេយ្យោ អមិត្តោ មេធាវី យញ្ចេ ពាលានុកម្បកោ
មុធិ អមិត្តោ និទ្ទោសោ  ពាលោ ទោសោ បទេ បទេ

បណ្ឌិតពុំជាមិត្រគន់ប្រសើរគាប់  ជាងសង្គ្រោះពាលរាប់ហ្មឺនពាន់
ពុំសេដ្ឋា  បណ្ឌិតនោះមិនមិត្រក៏ឥតឲ្យទោសា  ឯពាលមោហាឲ្យទោស
ពល់ជំហាន ។

សុភាសិតថា

កូនមានមតិគួរបើត្រិះគន់ កូនសូមឲ្យមតិលោកផងពុំស្ទើរ កូនកបមតិតែងឲ្យសុខា កូនសូមឲ្យមត្យាតែងឲ្យពោសព្យសន៍ ។

ឆត្តា[1] ឆទី អនោនកា ឆត្តំ រដ្ឋំ អភជិតំ
ឥត្ថីបិ វិធវា ឆត្តា យស្សាភិ ឧស់ ភាតកោ ។

ទន្លេស៊ីងឥតទឹកទុកជាស្រោត រដ្ឋឥតស្តេចពាក់ជារដ្ឋមេម៉ាយ ស្ត្រីវិធវាភាគប់ប្តីយ គង់លោះម៉ាយថាជាកំព្រាសុខ ។

បរេសតំ បេបិ សមាគតានំ
ឈាយេយ្យុ តេ វស្សសតំ អបញ្ញា
ឯកោវ សេយ្យោ បុរិសោ សបញ្ញោ
យោ ភាសិតស្ស វិជានាតិ អត្ថំ ។

ជនអ័ប្បប្រាជ្ញច្រើនកប់រយពាន់ ប្រជុំគ្នាគ្មានដោះអាចប្រស្នា អស់សតវត្សឥតបានការពារ ហេតុតែមោហាដូចបសុសត្វ ។ រីជនតែម្នាក់ កបញ្ញាណបញ្ញា គាចដោះប្រស្នាអត្ថបរមត្ថ ដឹងពាក្យសួរសៀត គាចឆ្លៀតឆ្លើយកាត់ ប្រសើរលើសគ្នាតបរិស័ទ្យពាល ។ (មានត)

---

១ ឆត្ត - ស័ព្ទនេះ ប្រែបានច្រើនយ៉ាងថា, ត្រូនិល, ថ្មុយ, រនល, ស្រាត, ស្រាតរនល អាក្រាត, ទទេ, មិនជាប់នៅ ... ។